**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-May-2012, 11:09
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យប្រភេទនៃចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញានៅនឹងបណ្តឹងរបស់ អៀង សារី ប្តឹងជំទាស់ចៅក្រម SILVIA CARTWRIGHT អនុលោមតាមវិធាន៣៤ ឬជាជម្រើសផ្សេង សំណើសុំការណែនាំ និងបង្គាប់ឲ្យបញ្ឈប់ និងឈប់ធ្វើការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* និងសំណើសុំឲ្យបង្ហាញអំពីការប្រាស្រ័យទាក់ទងនានាជាមួយ *តែភាគីម្ខាង***

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| **សហព្រះរាជអាជ្ញា:** | **អង្គជំនុំជម្រះសាលាដំបូង:** | **ជនជាប់ចោទ:** |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | នួន ជា |
| | ចៅក្រម យ៉ា សុខន | អៀង សារី |
| | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |
| | ចៅក្រម យូ ឧត្តរា | |
| | ចៅក្រមបម្រុង ធូ មន្នី | **មេធាវីការពារក្តីជនជាប់ចោទ:** |
| | ចៅក្រមបម្រុងClaudia FENZ | លោក សុន អរុណ |
| | | លោក Michiel PESTMAN |

| | |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីៈ** | លោក Victor Koppe |
| ពេជ អង្គ | លោក អាង ឧត្ដម |
| Elisabeth SIMONNEAU FORT | លោក Michael G.KARNAVAS |
| | លោក គង់ សំអុន |
| | លោកArthur VERCKEN |
| | លោក Jacques VERGÈS |
| | លោកស្រី Anta GUISSE |

# I. សេចក្តីផ្តើម និង ប្រវត្តិនីតិវិធី

១- នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១ មេធាវីការពារក្តី អៀង សារី (“មេធាវីការពារក្តី”) បានដាក់បណ្តឹងជិតចិត្តមួយប្រឆាំងនឹងចៅក្រម Cartwright តាមវិធាន៣៤ និងស្នើសុំបំពេញកិច្ចស៊ើបសួរមួយ តាមវិធាន៣៥ ដោយសំអាងទៅលើមូលដ្ឋាននៃការជួបប្រជុំផ្នែករដ្ឋបាលមួយ រវាងចៅក្រម Cartwright, អនុប្រធានរដ្ឋបាល លោក Knut Rosandhaug និងសហព្រះរាជអាជ្ញាអន្តរជាតិលោក Andrew Cayley (“សំណើលើកទីមួយ”)[1]។ សំណើសុំបំពេញកិច្ចស៊ើបសួរនេះ ស្វែងរក “ព័ត៌មានស្តីពីការប្រាស្រ័យទាក់ទងជាមួយ*ភាគីតែម្ខាង* រវាងលោក Cayley និងចៅក្រម Cartwright” រួមទាំងបញ្ជីរាយឈ្មោះនៃកិច្ចប្រជុំទាំងអស់, “អង្គហេតុ និងសេចក្តីពិស្តារពាក់ព័ន្ធទាំងអស់ទាក់ទិននឹង*កិច្ចប្រជុំជាមួយភាគីតែម្ខាង*, និងរបៀបវារៈនៃកិច្ចប្រជុំទាំងនេះ[2] ។

២- នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការដាក់ឯកសាររបស់មេធាវីការពារក្តី “មិនបានបំពេញលក្ខខណ្ឌតម្រូវដូចបានកំណត់ ស្តីពីភ័ស្តុតាងដែលចែងនៅក្នុងវិធាន៣៤” សម្រាប់ការប្តឹងជិតចិត្ត និង “គ្មានខ្លឹមសារ”[3]។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ផងដែរថា កិច្ចប្រជុំរដ្ឋបាលស្រដៀងគ្នានេះនៅតាមបណ្តាតុលាការអន្តរជាតិដទៃទៀត “គឺជារឿងធម្មតា” និង “ធានាដល់ប្រតិបត្តិការ និងការសម្របសម្រួលមានប្រសិទ្ធភាពចំពោះសកម្មភាពរដ្ឋបាល...ហើយជាចាំបាច់ និងសំខាន់បំផុត សម្រាប់ការដោះស្រាយលើបញ្ហាប្រឈមផ្នែករដ្ឋបាលតែមួយគត់ ដែលបានជួបប្រទះដោយតុលាការអន្តជាតិទាំងនោះ”[4]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា មេធាវីការពារក្តីខកខានមិនបានថ្លែងបញ្ជាក់ឲ្យបានគ្រប់គ្រាន់អំពីសំណើសុំបំពេញកិច្ចស៊ើបសួរតាមវិធាន៣៥ និងថាបើដូច្នេះ មិនបានសម្រេចទៅលើទឡ្ហីករណ៍នោះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបាន

[1] **E137/3** *សំណើរបស់ អៀង សារី សុំឲ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាងរវាងសហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយលោកស្រីចៅក្រម Cartwright និងអ្នកដទៃទៀត,* ២៤ វិច្ឆិកា ឆ្នាំ២០១១។ ក្រោយមកទៀត មេធាវីការពារក្តីអះអាងថាពួកគេគ្រាន់តែធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរតាមវិធាន៣៥ប៉ុណ្ណោះ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា មេធាវីការពារក្តីបានធ្វើបណ្តឹងជិតចិត្ត ហើយតុលាការកំពូល ខណៈដែលធ្វើការសម្រេចលើអំណះអំណាងរបស់មេធាវីការពារក្តីថា មានសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរដែរ បានតម្កល់ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការដាក់ឯកសារនោះមានសំណើប្តឹងជិតចិត្ត។

[2] **E137/3** *សំណើរបស់ អៀង សារី សុំឲ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាងរវាង សហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយ លោកស្រីចៅក្រម Cartwright និងអ្នកដទៃទៀត,* ២៤ វិច្ឆិកា ឆ្នាំ២០១១, ទំព័រ១។

[3] **E137/5** សេចក្តីសម្រេចលើបណ្តឹងជិតចិត្តលោកស្រីចៅក្រម Silvia Cartwright, ២ ធ្នូ ២០១១, កថាខណ្ឌទី២០។

[4] *ដដែលដូចខាងលើ,* កថាខណ្ឌទី១៩។

សម្រេចថា "សំណើរបស់ អៀង សារី សុំព័ត៌មានទាក់ទងនឹងកិច្ចប្រជុំទាំងនេះ ត្រូវបានដោះស្រាយគ្រប់គ្រាន់តាមរយៈអ៊ីម៉េលរបស់លោកអនុប្រធានរដ្ឋបាល ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១១ រួចហើយ"[5]។

៣- មេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍លើបញ្ហានេះដោយអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើបញ្ហានេះ និង "បានជៀតជ្រែកដោយចេតនា និងបានដឹងជាមុនទៅលើរដ្ឋបាលតុលាការតាមរយៈការខកខានមិនបានស៊ើបអង្កេតលើកិច្ចប្រជុំ *ជាមួយភាគីតែម្ខាង* ទាំងអស់នេះទេ"[6]។

៤- នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការដាក់ឯកសាររបស់មេធាវីការពារក្តីអំពីសំណើសុំបំពេញកិច្ចស៊ើបសួរមួយ តាមវិធាន៣៥[7] ប៉ុន្តែពុំមានសម្អាងហេតុឡើយ[8] អាស្រ័យហេតុនេះ អង្គជំនុំជម្រះក៏បដិសេធបណ្តឹងឧទ្ធរណ៍នេះចោល[9]។ អង្គជំនុំជម្រះក៏បានធ្វើការកត់សម្គាល់បន្ថែមថា: យោងតាមលោក Rosandhaug គោលបំណងនៃកិច្ចប្រជុំរបស់ពួកគាត់គឺមិនមែនដើម្បីធ្វើឲ្យមានការអាក់អន់ស្រពន់ចិត្តទេ ប៉ុន្តែដើម្បីជួយសម្រួលដល់ដំណើរការនីតិវិធីសវនាការ។ *មេធាវីការពារក្តីមិនបានជំទាស់នឹងការអះអាងនេះទេ* ហើយបានយល់ស្របថា គោលបំណងស្រដៀងគ្នានេះ ក៏បានធ្វើឡើងដោយក្រុមប្រឹក្សាសម្របសម្រួលដែលបានប្រព្រឹត្តទៅ នៅតាមបណ្តាតុលាការអន្តរជាតិដទៃទៀតដែរ"[10]។ ក្រោយពីមានការបដិសេធលើបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី អង្គជំនុំជម្រះតុលាការកំពូលក៏បានថ្លែងផងដែរថា:

> *និយាយថា ដោយគ្មានមូលដ្ឋានអំពីស្ថាប័នណាមួយទាំងនៅក្នុងឯកសារបង្កើត អ.វ.ត.ក និងទាំងនៅក្នុងវិធានផ្ទៃក្នុង កិច្ចប្រជុំដូច្នេះអាចឲ្យគេដឹងបានថាមានការពាក់ព័ន្ធទៅនឹងករណីណាមួយ ឬច្រើនដែលចៅក្រមបានចូលរួមនោះមានការបារម្ភ។ ដូច្នេះ ពួកគាត់អាច*

---

[5] *ដដែលដូចខាងលើ,* កថាខណ្ឌទី២០។

[6] **E137/5/1/1** បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីបណ្តឹងជិតចិត្តលោកស្រីចៅក្រម Silvia Cartwright, ថ្ងៃទី៥ មករា ២០១២, កថាខណ្ឌទី៤៧។

[7] **E137/5/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីបណ្តឹងជិតចិត្តលោកស្រីចៅក្រម Silvia Cartwright, ថ្ងៃទី១៧ មេសា ២០១២។

[8] *ដដែលដូចខាងលើ,* កថាខណ្ឌទី២៣។

[9] *ដដែលដូចខាងលើ,* ទំព័រទី១០។

[10] *ដដែលដូចខាងលើ,* កថាខណ្ឌទី២៣ (សង្កត់ន័យត្រង់អក្សរទ្រេត)។

> *បង្កើតឱ្យមាននូវភាពប្រាកដឡើងនៃលទ្ធភាពទទួលបាននូវសមប្បមាណ ដែលអំណោយផលដល់ព្រះរាជអាជ្ញាចំពោះចៅក្រមជំនុំជម្រះ។ អាស្រ័យហេតុនេះ ដើម្បីជៀសវាងកុំឱ្យមានភាពប្រាកដឡើងដូច្នេះ និងនាំឱ្យមានសំណើសុំជិតចិត្ត គេគួរតែមើលឃើញថា នេះជាការជូនយោបល់ឱ្យពិចារណាឡើងវិញ ចំពោះការបង្កើតឱ្យមានការជួបប្រជុំណាមួយដែលចៅក្រមជំនុំជម្រះមានបំណងចង់ធ្វើជាមួយព្រះរាជអាជ្ញាតាមរយៈការអនុញ្ញាតឱ្យមានការចូលរួមពីក្រុមមេធាវីការពារក្តី តាមការសមស្រប*[11]។

ដោយធ្វើការកត់សម្គាល់អំពីយុត្តាធិការមានកំណត់របស់ខ្លួន ដោយមិនរាប់បញ្ចូលបណ្ដឹងសាទុក្ខភ្លាមៗតាមវិធាន៣៤[12] អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់ការបដិសេធ របស់អង្គជំនុំជម្រះសាលាដំបូងលើបណ្ដឹងជិតចិត្តដែលបរាជ័យរបស់មេធាវីការពារក្ដីចំពោះចៅក្រម Cartwright ថាជាសេចក្ដីសម្រេចស្ថាពរ *(អាជ្ញាអស់ជំនុំ)* លើផ្នែកនៃការដាក់ឯកសារ។

៥- ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ ពីរថ្ងៃបន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់ការណែនាំនេះ ចៅក្រម Cartwright បានបញ្ជូនអ៊ីម៉ែលមួយទៅកាន់បញ្ជីចែកចាយការជូនដំណឹងនៅក្នុងសំណុំរឿង ដែលជាផ្នែកមួយនៃការពិភាក្សាដោយសង្ខេប ទាក់ទងនឹងរបៀបនៃការធានាចំពោះការអនុវត្តទៅតាមខ្លឹមសារនៃលិខិតនោះ និងទៅតាមស្មារតីនៃគោលការណ៍ណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល។ អ៊ីម៉ែលនោះបញ្ជាក់ថា: តាមពិត ខ្ញុំកំពុងតែព្យាយាមធ្វើយ៉ាងណា ដើម្បីបានឃើញអំពីភាពធូរស្រាលជាងនេះ។ ដូចលោកស្គាល់ Andrew ហើយ, ខ្ញុំកំពុងតែពិចារណាយ៉ាងយកចិត្តទុកដាក់បំផុតអំពីមុខតំណែងរបស់ខ្ញុំ។ ខ្ញុំមិនត្រូវធ្វើការសម្រេចចិត្តរបស់ខ្ញុំរហ័សរហួននោះទេ Silvia”[13]។ បំណងចំពោះអ្នកទទួលអ៊ីម៉ែលនេះ ត្រូវបានសួរដេញដោលដោយមេធាវីការពារក្ដី។ ជាការឆ្លើយតប នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់នូវការពន្យល់ផ្សេងៗដូចខាងក្រោមនេះថា:

[11] *ដដែលដូចខាងលើ,* កថាខណ្ឌទី២៤។

[12] *ដដែលដូចខាងលើ,* កថាខណ្ឌទី១១។

[13] **E191.1** អ៊ីម៉ែលពីចៅក្រម Silvia Cartwright ផ្ញើទៅកាន់បញ្ជីចែកចាយនៃការជូនដំណឹងសំណុំរឿង, ១៩ មេសា ២០១២។

*សារក្នុងអ៊ីម៉េលដែលបានផ្ញើជូនកាលពីម្សិលមិញទៅកាន់អ្នកទទួលមួយចំនួន គឺក្នុងគោលបំណងបញ្ជូនទៅកាន់លោកអនុប្រធានរដ្ឋបាល និងសហព្រះរាជអាជ្ញាអន្តរជាតិលោក Andrew Cayley។*

*សារនេះ គឺជាផ្នែកមួយនៃកិច្ចពិភាក្សាដោយសង្ខេបក្នុងចំណោមចៅក្រម Cartwright, លោក Andrew Cayley និងលោក Rosandhaug ទាក់ទងនឹងប្រតិកម្មសមស្របទៅនឹងសេចក្តីសម្រេចថ្មីៗនេះរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលនៅក្នុងសេចក្តីសម្រេចនេះ បណ្តឹងសាទុក្ខមួយប្រឆាំងការបដិសេធមិនដកចៅក្រមCartwright ត្រូវបានបដិសេធ។ កិច្ចប្រជុំស្តីពីការគ្រប់គ្រង ដែលជាកម្មវត្ថុនៃសំណើសុំឱ្យដកចៅក្រមរូបនេះ ដែលពីដើមដំបូងត្រូវបានធ្វើឡើងតាមសំណើរបស់ការិយាល័យទទួលបន្ទុកកិច្ចការច្បាប់ ប៉ុន្តែតាមស្មារតីនៃការផ្តល់យោបល់របស់ អជតក សេចក្តីសម្រេចផ្អាកមួយត្រូវបានធ្វើឡើង[14]។*

៦- មេធាវីការពារក្តីបានដាក់បណ្តឹងជំទាស់ និងសំណើសុំនេះ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២[15]។ បណ្តឹងជំទាស់ និងសំណើសុំនេះស្វែងរកដើម្បីធ្វើឱ្យរស់ឡើងវិញនូវបណ្តឹងជំទាស់ និងសំណើសុំបំពេញកិច្ចស៊ើបសួរដែលទទួលបរាជ័យ ដោយអះអាងថា ភ័ស្តុតាងក្នុងប្រភេទដូចគ្នានេះនៃកិច្ចពិភាក្សាផ្នែករដ្ឋបាល ដែលគេបានពឹងផ្អែកសម្រាប់ជាការសន្និតចំពោះសារណាពីមុនៗរបស់ខ្លួន ហើយដែលបានច្រានចោលទាំងស្រុងដោយអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល បានក្លាយជាភ័ស្តុតាងនៃ "ការសន្ទនាជាមួយ *តែភាគីម្ខាង* ទាក់ទងនឹងបែបបទជាយុទ្ធសាស្ត្រ និងប្រកបដោយល្បិចកលនៃរបៀបដំណើរការ"[16]។ មេធាវីការពារក្តីប្តឹងជំទាស់លោកស្រីចៅក្រម Cartwright ដោយផ្អែកលើទឡ្ហីករណ៍នៃភាពលម្អៀងជាក់ស្តែង និងការកើតឡើងនៃភាពលម្អៀង; ការណែនាំដល់លោកស្រីចៅក្រម Cartwright និងបង្គាប់ឱ្យសហព្រះរាជអាជ្ញាអន្តរជាតិលោក Andrew Cayley ឱ្យបញ្ឈប់ការប្រាស្រ័យទាក់ទងគ្នាបន្តទៀត និងការណែនាំឱ្យលោកស្រីចៅក្រម

---

[14] **E191.1.3** អ៊ីម៉េលពីលោកស្រី Susan Lamb ជូនមេធាវីការពារក្តី អៀង សារី, ២០ មេសា ២០១២ និងអ៊ីម៉េលពីមេធាវីការពារក្តី អៀង សារី ជូនគូភាគី, ២០ មេសា ២០១២។

[15] **E191** បណ្តឹងជំទាស់លោកស្រីចៅក្រម Silvia Cartwright របស់ អៀង សារី អនុលោមតាមវិធាន៣៤ ឬជាជម្រើសផ្សេង សំណើសុំការណែនាំ និងបង្គាប់ឱ្យបញ្ឈប់ និងឈប់ធ្វើការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* និងសំណើឱ្យបង្ហាញអំពីការប្រាស្រ័យទាក់ទងនានាជាមួយ *តែភាគីម្ខាង*, ២៧ មេសា ឆ្នាំ២០១២ ("បណ្តឹងជំទាស់ និងសំណើ")។

[16] *ដដែលដូចខាងលើ*, កថាខណ្ឌទី៧។

Cartwright និងបង្គាប់ឱ្យសហព្រះរាជអាជ្ញាអន្តរជាតិលោក Andrew Cayley បង្ហាញគ្រប់ការប្រាស្រ័យទាក់ទងគ្នាទាំងអស់ តាំងពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១ និងព័ត៌មានទាក់ទងនឹងកិច្ចប្រជុំណាមួយដែលបានធ្វើឡើង[17]។

៧- សហព្រះរាជអាជ្ញាឆ្លើយតបថា បណ្តឹងជំទាស់ចៅក្រមនេះ មិនអាចទទួលយកបានឡើយ ដោយសារតែខកខានមិនបានបង្ហាញភស្តុតាងពាក់ព័ន្ធណាមួយ ដើម្បីគាំទ្រចំពោះអំណះអំណាង *មួយក្រឡេកមើល* របស់ខ្លួន និងខកខានមិនបានបំពេញបន្ទុកនៃភស្តុតាងចំពោះសំណើសុំប្តឹងជំទាស់ចៅក្រម ដើម្បីបង្ហាញឱ្យឃើញថា ចៅក្រម Cartwright ពិតជាមានភាពលម្អៀងមែន ឬក៏ត្រូវបានអ្នកសង្កេតការណ៍ឯករាជ្យ និងប្រកបដោយហេតុផល មើលឃើញថាអាចនឹងលម្អៀង។ ដូចគ្នានេះដែរ ការសុំឱ្យបង្ហាញ និងឱ្យ "ឈប់ និងលែងឱ្យមាន" សំណើនេះគួរបានបដិសេធចោល ដោយសារវាហួសពីវិសាលភាពនៃវិធាន ៣៤។ លើសពីនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការបង្ហាញសំណើនេះមានតម្លៃស្មើនឹងការប៉ុនប៉ងលាក់លៀម ចំពោះការតវ៉ាជាថ្មីលើបញ្ហាដែលបានពិចារណា និងច្រានចោលពីដំបូងរួចហើយ តាមផ្លូវតុលាការ ដោយអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល[18]។

## II. បណ្តឹងជំទាស់ចៅក្រមគួរត្រូវបានបដិសេធចោល

៨- វិធាន៣៤ គ្របដណ្តប់ទៅលើបណ្តឹងជំទាស់ចៅក្រម ចែងថា:

> *ភាគីអាចធ្វើបណ្តឹងជំទាស់ចំពោះចៅក្រមណាម្នាក់ នៅក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឱ្យមានភាពលម្អៀងជាសត្យានុម័ត*[19]។

[17] *ដដែលដូចខាងលើ,* ទំព័រទី៩។

[18] **E137/5/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីបណ្តឹងជំទាស់ចៅក្រមលោកស្រីចៅក្រម Silvia Cartwright, ១៧ មេសា ២០១២។ **E137/5** សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមលោកស្រីចៅក្រម Silvia Cartwright, ២ ធ្នូ ២០១១។

[19] វិធាន៣៤(២) នៃវិធានផ្ទៃក្នុង។

## ក. បណ្ដឹងជិតចិត្ត មិនអាចទទួលយកបានទេ

៩- វិធាន៣៤ ចែងអំពីលក្ខខណ្ឌតម្រូវសម្រាប់ការទទួលយកបណ្ដឹងជិតចិត្តចំពោះចៅក្រមណាម្នាក់។ ជាពិសេស អនុវិធាន(៣), (៤) និង (៥) មានចែងពីលក្ខខណ្ឌតម្រូវដែលកំណត់អំពីភាពអាចទទួលយកបាន។ មេធាវីការពារក្ដី ដែលជាភាគីដាក់ឯកសារតម្រូវឲ្យ: (i) "បញ្ជាក់អំពីទង្វើករណ៍ឲ្យបានច្បាស់លាស់", (ii) "ផ្ដល់ភ័ស្ដុតាងគាំទ្រ", (iii) ដាក់បណ្ដឹងឲ្យបានឆាប់ (មានន័យថា "ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ") និង (iv) ដាក់បណ្ដឹងដែលពាក់ព័ន្ធនឹងចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ទៅអង្គជំនុំជម្រះឲ្យបានមុនពេលមានសេចក្ដីសម្រេចចុងក្រោយ។ លក្ខខណ្ឌតម្រូវទាំងនេះគឺមានលក្ខណៈរួមបញ្ចូលគ្នា។

១០- លក្ខខណ្ឌតម្រូវអំពីភាពអាចទទួលយកបានមានចែងនៅក្នុងវិធាន៣៤ គឺជាយន្តការត្រងចាប់ ដើម្បីរារាំងមិនឲ្យមានការប្រើពេលវេលា និងធនធានរបស់តុលាការមិនត្រឹមត្រូវ ក្នុងការដោះស្រាយបណ្ដឹងណាមួយដែលគ្មានមូលដ្ឋាន ឬគ្មានខ្លឹមសារ។ ការណ៍នេះ គឺស៊ីសង្វាក់គ្នាទាំងស្រុងទៅនឹងគំរូដែលបានអនុម័តនៅក្នុងវិធានស្ដីពីនីតិវិធី និងភ័ស្ដុតាងរបស់តុលាការអន្តរជាតិនានា រួមទាំង បទបញ្ជាផ្សេងៗទៀតរបស់តុលាការ នៅក្នុងការដោះស្រាយបណ្ដឹងអំពីទង្វើមិនត្រឹមត្រូវរបស់ចៅក្រម ឬព្រះរាជអាជ្ញាណាម្នាក់។ អត្ថបទច្បាប់ទាំងនេះណែនាំឲ្យប្រធានធ្វើការវាយតម្លៃបឋម និងទុកមិនចាត់ការចំពោះបណ្ដឹង "អនាមិក ឬគ្មានមូលដ្ឋាន"[20] ដោយពុំចាំបាច់ពិចារណាបន្ថែមទៀតឡើយ។ តុលាការសិទ្ធិមនុស្សអឺរ៉ុប គណៈកម្មការទទួលបន្ទុកសិទ្ធិមនុស្សអន្តរអាមេរិកកាំង និងគណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម អះអាងដូច្នេះថាបណ្ដឹងណាដែល "គ្មានមូលដ្ឋានជាក់ស្ដែង" ឬ "គ្មានសំអាងហេតុ" *មិនអាចឲ្យទទួលបានឡើយ* បើសិនជាបណ្ដឹងនោះខកខានមិនបានបង្ហាញ យ៉ាងហោចណាស់ នូវមូលដ្ឋាននៃភ័ស្ដុតាង*ដែលអាចឲ្យគេសន្មតបានក្នុងមួយក្រឡេកម៉្ភក* ឬក៏បានផ្អែកទៅលើការស្មាន[21]។

---

[20] វិធានស្ដីពីនីតិវិធី និងភ័ស្ដុតាងរបស់តុលាការ ICC, វិធាន 26(2); បញ្ជាផ្ទៃក្នុងរបស់តុលាការ ICC, បញ្ជាផ្ទៃក្នុងលេខ 120-121។

[21] សម្រាប់ ECHR, *សូមអាន: Gomes ទល់នឹងស៊ុយអែត* (សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកបាន, ពាក្យបណ្ដឹងលេខ 34566/04, ៧ កុម្ភៈ ២០០៦) ត្រង់ទំព័រទី១១ (តម្រូវឲ្យមាន "ទង្វើករណ៍ជាសារធាតុដើម្បីឲ្យជឿបាន" ថាជាលក្ខខណ្ឌកំណត់សម្រាប់ការទទួលយក)។ សម្រាប់ IACHR, *សូមអាន: Monsi Lilia Velarde Retamozo ទល់នឹងប្រទេសប៉េរូ*, សំណុំរឿង 12.165, របាយការណ៍លេខ 85/03, Inter-Am. C.H.R., OEA/Ser.L/V/II.118 Doc. 70 វិសោធនកម្មលើកទី២ ត្រង់ 437 (២០០៣) ត្រង់កថាខណ្ឌទី៤៥។ សូមអានផងដែរ *V. ទល់នឹងប្រទេសបូលីវៀ*, សំណុំរឿង 270-07, របាយការណ៍លេខ 40/08, Inter-Am. C.H.R., OEA/Ser.L/V/II.130 Doc. 22, វិសោធនកម្មលើកទី១ (២០០៨) ត្រង់កថាខណ្ឌ 79។ *Herrera y Vargas (La Nación)*, Costa Rica, សំណុំរឿងលេខ 12,367, ៣ ធ្នូ, IACHR, របាយការណ៍លេខ 128/01, 2001 ត្រង់កថាខណ្ឌទី 50។ របាយការណ៍លេខ 4/04, បណ្ដឹង 12,324, *Rubén*

សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងអនុវត្តបទដ្ឋានស្រដៀងគ្នានេះ នៅក្នុងការសម្រេចលើបណ្តឹងជិតចិត្ត និងសំណើសុំ។

១១- បណ្តឹងជិតចិត្តខកខានមិនបានបំពេញលក្ខខណ្ឌកំណត់សម្រាប់ការទទួលយកទេ ដោយសារបណ្តឹងនេះមិនបានបង្ហាញនូវមូលដ្ឋាននៃភ័ស្តុតាង ដើម្បីគាំទ្រដល់មូលហេតុនៃការប្តឹងជិតចិត ដូចមេធាវីការពារក្តីបានអះអាងទេ។ ភាគច្រើនបំផុត មេធាវីការពារក្តីបានផ្តល់ភ័ស្តុតាងពាក់ព័ន្ធនឹងកិច្ចប្រជុំរដ្ឋបាល ដែលខ្លួនបានតវ៉ារួចហើយនៅក្នុងបណ្តឹងជិតចិត្តភ្លាមៗលើកមុនៗរបស់ខ្លួន ចំពោះលោកស្រីចៅក្រម Cartwright ដែលបណ្តឹងនោះត្រូវបានអង្គជំនុំជម្រះសាលាដំបូង សម្រេចថា "គ្មានខ្លឹមសារទាល់តែសោះ"[22]។ អ៊ីម៉េលពីលោកស្រីចៅក្រម Cartwright បង្ហាញពីស្ថាប័នរដ្ឋបាលពិភាក្សាពីរបៀបដែលត្រូវយកចិត្តដាក់ឲ្យបានសមរម្យ ចំពោះសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល ភ្លាមៗបន្ទាប់ពីមានការណែនាំនោះ។ អំណះអំណាងគាំទ្ររបស់មេធាវីការពារក្តីដែលនៅសេសសល់ សម្រាប់ការប្តឹងជិតចិត្តនេះ គឺមានវិការៈលើការស្មានៗអំពី "ការបណ្តោយឲ្យមានសភាពការណ៍មួយលេចឡើងច្បាស់"[23] និង "ការសន្ទនាជាមួយ*តែភាគីម្ខាង* ទាក់ទងនឹងបែបបទជាយុទ្ធសាស្ត្រ និងប្រកបដោយល្បិចកលធ្វើយ៉ាងណាដើម្បីដកចេញពីសេចក្តីសម្រេចរបស់ អជតក"[24]។ ហេតុដូច្នេះ មេធាវីការពារក្តីខកខានមិនបានបំពេញបន្ទុកនៃភ័ស្តុតាង *ដែលអាចឲ្យគេសន្និដ្ឋានបានក្នុងមួយក្រឡេកភ្នែក* សម្រាប់ការទទួលយក ហើយអង្គជំនុំជម្រះសាលាដំបូងគួរបដិសេធចោលបណ្តឹងនេះ ដោយសារតែមិនអាចទទួលបានតាមវិធាន៣៤(៣)។

## ខ. ទោះបីជាបណ្តឹងជិតចិត្តអាចទទួលយកបានក៏ដោយ

*Luis Godoy*, ប្រទេសអាហ្សង់ទីន, ២៤ កុម្ភៈ ២០០៤ ត្រង់កថាខណ្ឌទី៤៣ និង របាយការណ៍លេខ 29/07, បណ្តឹង 712-03, *Elena Tellez Blanco*, ប្រទេសកូស្តារីកា, ២៦ មេសា ២០០៧, ត្រង់កថាខណ្ឌទី៥៨។ សម្រាប់ CAT សូមអានៈ អនុសាសន៍ទូទៅលេខ 01: ការអនុវត្តមាត្រា៣ នៃអនុសញ្ញា ក្នុងបរិបទនៃមាត្រា២២ (11/21/1997) A/53/44, ឧបសម្ព័ន្ធ IX, អនុសាសន៍ទូទៅនៃអនុសញ្ញា CAT លេខ 01 (អនុសាសន៍ទូទៅ) ត្រង់កថាខណ្ឌទី៤-៦។ 6 *H.I.A. ទល់នឹងប្រទេសស៊ុយអែត*, ការប្រាស្រ័យទាក់ទងលេខ 216/2002, ឯកសាររបស់អង្គការសហប្រជាជាតិ CAT/C/30/D/216/2002 (2003) (សេចក្តីសម្រេចរបស់គណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្ម ក្រោមមាត្រា២២ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងអំពើឃោរឃៅដទៃទៀត, ប្រព្រឹត្តិកម្ម ឬការផ្តន្ទាទោសដោយអមនុស្សធម៌ ឬមានលក្ខខណៈបន្ទាបបន្ថោក - សម័យប្រជុំលើកទី៣០ - ការប្រាស្រ័យទាក់ទងលេខ 216/2002) ត្រង់កថាខណ្ឌទី៦.១-៦.២។

[22] **E137/5** *កំណត់សម្គាល់ខាងដើម* លេខ៣, កថាខណ្ឌទី២០។

[23] **E191** *កំណត់សម្គាល់ខាងដើម* លេខ១៥, កថាខណ្ឌទី១០។

[24] **E191** *កំណត់សម្គាល់ខាងដើម* លេខ១៥, កថាខណ្ឌទី៧។

## កំហុសមេធាវីការពារក្តីខកខានមិនបានបំពេញបន្ទុកនៃភស្តុតាងដ៏មានទម្ងន់របស់ខ្លួនបានឡើយ

១២- មេធាវីការពារក្តីអះអាងថា ចៅក្រម Cartwright ពិតជាលម្អៀង ឬតាមរបៀបផ្សេងពីនេះ ពួកគេនិយាយថា ភស្តុតាងរបស់ពួកគេបង្ហាញឲ្យឃើញនូវការកើតឡើងនៃភាពលម្អៀង[25]។ ដូចអង្គជំនុំជម្រះតុលាការកំពូលបានអះអាងនាពេលថ្មីៗនេះថា "ភាគីដែលអនុវត្តវិធាន៣៤ ត្រូវបង្ហាញឲ្យឃើញថា ចៅក្រមពិតជាមិនអាចដោះស្រាយវិវាទណាមួយដោយគ្មានភាពលម្អៀង ឬថាមានការកើតឡើងនូវកង្វះខាតភាពលម្អៀងដោយសត្យានុម័ត នៅក្នុងករណីជាក់លាក់ណាមួយ"[26]។ មេធាវីការពារក្តីខកខាននៅលើចំណុចទាំងពីរនេះ។ ទាំងភស្តុតាងនៃការប្រាស្រ័យទាក់ទងនៅថ្ងៃទី១៩ ខែមេសា និងទាំងភស្តុតាងនៃការប្រាស្រ័យទាក់ទងថ្ងៃទី២០ ខែមេសា ដែលមេធាវីបានដាក់ មិនបានបង្ហាញមូលដ្ឋានសម្រាប់គាំទ្រដល់បណ្តឹងទេ។

### *i. ការប្រាស្រ័យទាក់មិនជាប់ពាក់ព័ន្ធជាមួយនឹងខ្លឹមសារនៃដំណើរការនីតិវិធីនោះទេ*

១៣- ថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានសង្កេតឃើញថា ប្រសិនជា "ការប្រាស្រ័យទាក់ទងរវាងសហព្រះរាជអាជ្ញាជាមួយនឹងចៅក្រមមួយរូប... មិនទាក់ទាក់ទងជាមួយនឹងខ្លឹមសារនៃដំណើរការនីតិវិធីទេក្នុងករណីណាក៏ដោយ ការប្រាស្រ័យទាក់ទង*ជាមួយភាគីតែម្ខាង* ដែលបានធ្វើឡើងនេះ គឺមិនមែនដើម្បីបង្ហាញពីភាពលម្អៀង ឬឲ្យឃើញជារូបភាពខាងក្រៅថាលម្អៀងនោះឡើយ"[27]។

១៤- ភស្តុតាងដែលបានលើកឡើងដោយមេធាវីការពារក្តី ក្នុងគ្រប់ករណីទាំងអស់ គឺមិនមែនអំពីការប្រាស្រ័យទាក់ទងដែលពាក់ព័ន្ធនឹងខ្លឹមសារនៃដំណើរការនីតិវិធីនោះឡើយ។ មនុស្សសំខាន់ៗដែលចូលរួមនៅក្នុងការប្រជុំទាំងនេះ ដែលជាផ្នែកនៃមុខងាររដ្ឋបាលរបស់ខ្លួន បានពិនិត្យពិចារណាដោយគោរពទៅតាម*ខ្លឹមសារសេចក្តីសម្រេចពីមុនដែលគ្មានភាពចាំបាច់សម្រាប់ការធ្វើសេចក្តីសម្រេចលើរឿងក្តី*ទេរបស់អង្គជំនុំជម្រះតុលាការកំពូលដែលទាក់ទងនឹងការដឹកនាំនៃការប្រជុំទាំងនេះ។ ពួកគេត្រូវតែធ្វើដូចនេះ។ នៅពេលដែល *ខ្លឹមសារនៃសេចក្តីសម្រេចពីមុនដែលគ្មានភាពចាំបាច់សម្រាប់ការធ្វើសេចក្តី*

---

[25] *ដដែលដូចខាងលើ។*

[26] **E137/5/1/3** *កំណត់សម្គាល់ខាងដើម* លេខ៧, កថាខណ្ឌទី១៥។

[27]ឯកសារលេខ**E137/5** កំណត់សម្គាល់លេខ៣ *ពីខាងដើម* កថាខណ្ឌទី១៦។

*សម្រេចលើរឿងក្តីទេ* របស់អង្គជំនុំជម្រះតុលាការកំពូល មិនមានចរិតបង្ខំត្រូវតែជាប់កាតព្វកិច្ចអនុវត្ត តាមនោះក្តី ក៏នៅតែមានទម្ងន់ដ៏ធ្ងន់ និងចាំបាច់ត្រូវឱ្យធ្វើការពិនិត្យពិចារណាដែរ។ ការពិនិត្យពិចារណានេះ គឺគ្មានជាប់ទាក់ទងបែបណាមួយទៅនឹងខ្លឹមសារនៃដំណើរការនីតិវិធីនៃសវនាការជំនុំជម្រះក្តីដែលកំពុងតែប្រព្រឹត្តទៅលើសំណុំរឿងលេខ០០២នោះឡើយ។

១៥- មេធាវីការពារក្តីមិនអាចសំអាងលើអំណាចនៃការដាក់ពាក្យសុំនេះ ដើម្បីប្តឹងជំទាស់និងសុំឱ្យធ្វើការស៊ើបអង្កេតទៅលើលោកស្រីចៅក្រម Cartwright -ដោយផ្អែកលើមូលដ្ឋាននៃការប្រជុំរដ្ឋបាលដែលបានធ្វើឡើងចុងក្រោយ គឺមិនជាប់ទាក់ទងជាមួយនឹងខ្លឹមសារនៃដំណើរការនីតិវិធីនៅក្នុងសំណុំរឿងលេខ០០២ឡើយ និងមិនបង្ហាញអំពីមូលហេតុដែលនាំឱ្យមានការស៊ើបអង្កេតនោះទេ - ហើយបន្ទាប់មកទៀត ក៏លើកឡើងអះអាងដោយសមហេតុសមផលថា សេចក្តីសម្រេចលើបណ្តឹងសាទុក្ខមួយដែលចាំបាច់ត្រូវពិភាក្សាក្នុងកិច្ចប្រជុំដែលដូចៗគ្នា ដែលតាមរយៈនេះ *គឺវាបានធ្វើឱ្យក្លាយទៅជា* មានការជាប់ពាក់ព័ន្ធទៅនឹងដំណើរការនីតិវិធីនៅក្នុងសំណុំរឿងលេខ០០២[28]ទៅវិញ។

១៦- តាមពិត ពាក្យថា "*ជាមួយភាគីតែម្ខាង*"នេះ ត្រូវបានយកមកប្រើដោយខុសនៅក្នុងស្ថានភាពបែបនេះ ព្រោះវាជាពាក្យច្បាប់ដែលមានលក្ខណៈបែបសិល្បៈមួយ ដែលរៀបរាប់អំពីការប្រាស្រ័យទាក់ទងគ្នាដោយភាគីមួយជាមួយនឹងចៅក្រមមួយរូប ស្តីពីខ្លឹមសារនៃដំណើរការនីតិវិធីនៅចំពោះមុខចៅក្រមរូបនោះ ដោយមិនមានភាគីផ្សេងទៀតនៅក្នុងនោះទេ។ នៅពេលដែលការប្រាស្រ័យទាក់ទងគ្នាពាក់ព័ន្ធនឹងបញ្ហានានាដែលទាក់ទងនឹងកិច្ចការរដ្ឋបាលរបស់ អវតក នោះ គឺគ្មាន "ដំណើរការនីតិវិធី" ណាមួយដែលនៅក្នុងនោះ លោកស្រីចៅក្រម Cartwright បំរើការងារក្នុងឋានៈជាតុលាការ មិនមែន

[28] ដើម្បីដាក់សំណើទាមទារសុំរបស់មេធាវីការពារក្តីឱ្យស្ថិតក្នុងភាពកំពុងជាប់បន្ទុក , ឧទាហរណ៍មួយស្តីពីការប្រាស្រ័យទាក់ទងអំពីបញ្ហាដែលជាប់ទាក់ទងយ៉ាងពិតប្រាកដទៅនឹងខ្លឹមសារនៃដំណើការនីតិវិធី នោះគឺការពិភាក្សា *ជាមួយភាគីតែម្ខាង* ស្តីពីថាតើសាក្សីមួយចំនួនមុខជាទទួលយល់ព្រម ឬមិនយល់ព្រម។ តាមពិត ផ្ទុយពីការពោលអះអាងរបស់មេធាវីការពារក្តីដែលថា "តាមអ្វីដែលពួកគេបានដឹងច្បាស់បំផុតនោះ គឺគ្មានក្រុមមេធាវីការពារក្តីណាបានខិតខំព្យាយាមដើម្បីប្រាស្រ័យទាក់ទង *ជាមួយភាគីតែម្ខាង* ជាមួយនឹងសមាជិករបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងអំពីដំណើរការនីតិវិធីក្នុងសំណុំរឿងលេខ០០២នោះទេ", ពួកគេត្រូវការចាំបាច់ដើម្បីចាំមើលការដាក់ឯកសាររបស់មេធាវីការពាររបស់ នួន ជា មិនឱ្យហួសពីថ្ងៃទី១៦ មីនា ២០១២ បើសិនជា ពួកគេមានមោទនភាពដើម្បីលើកឡើងថា "មេធាវីការពារក្តីត្រូវបានគេផ្តល់ព័ត៌មានឱ្យដឹងដោយមិនផ្លូវការដោយអ្នកតំណាងមួយរូបរបស់អង្គជំនុំជម្រះសាលាដំបូងថា []តាមការពិត សាក្សីមួយចំនួននឹងមិនត្រូវបានគេធ្វើការកោះហៅមកទេ"។ ឯកសារលេខ **E182** សំណើរបស់ នួន ជា សុំឱ្យធ្វើការស្តាប់ចម្លើយសាក្សីនានារបស់មេធាវីការពារក្តី និងសុំឱ្យចាត់វិធានការផ្សេងៗទៀតផ្នែកនីតិវិធី ដើម្បីវាយតម្លៃឱ្យបានត្រឹមត្រូវទៅលើបរិបទស្តីពីប្រវត្តិសាស្ត្រ, ចុះថ្ងៃទី១៦ មីនា ២០១១, ត្រង់កថាខណ្ឌទី៤, កំណត់សម្គាល់លេខ៨។

ក្នុងឋានៈជារដ្ឋបាលនោះឡើយ។ ហេតុដូចនេះ គឺគ្មាន"ភាគី"ផ្សេងទៀតដែលបានអះអាងថាធ្វើជាអ្នកតំណាងនៅក្នុងកិច្ចពិភាក្សាបែបដូចនេះឡើយ។ អាស្រ័យហេតុនេះ ការប្រាស្រ័យទាក់ទងទាំងនេះ គឺវាមិនមែន "*ជាមួយភាគីតែម្ខាង*" នោះឡើយ។

*ii. បើសិនជាការប្រាស្រ័យទាក់ទងស្តីពីថាតើត្រូវអនុវត្តតាមការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលតាមរបៀបដូចម្តេច ដែលត្រូវគេយល់ឃើញថាទាក់ទងនឹងខ្លឹមសារនៃដំណើរការនីតិវិធីនោះក៏ដោយ ក៏មេធាវីការពារក្តីខកខានមិនបានបង្ហាញឱ្យឃើញជារូបរាងថាលម្អៀង ឬ លម្អៀងជាក់ស្តែងនោះដែរ*

១៧- ដូចដែលអង្គជំនុំជម្រះបានដឹងច្បាស់ហើយថា ចំណុចផ្តើមនៃការកំណត់សម្រេចណាមួយចំពោះការចោទប្រកាន់អំពីថាមានភាពលម្អៀង គឺជាការសន្មតទុកជាមុនថាមិនទាន់មានភាពលម្អៀង ដែលចៅក្រមទាំងអស់របស់ អវតក ត្រូវតែមានជាប់ ដោយផ្អែកលើមូលដ្ឋាននៃសម្បថចូលកាន់តំណែងនិងគុណវុឌ្ឍិផ្សេងៗសម្រាប់ការតែងតាំងជាចៅក្រម[29]។ ការសាកល្បងនេះបង្កើតជាឧបសគ្គ ពីព្រោះ "នៅពេលមានរូបរាងបង្ហាញពីភាពលម្អៀង ឬមានភាពលម្អៀងជាក់ស្តែងណាមួយពីសំណាក់ចៅក្រមណាម្នាក់ គឺធ្វើឱ្យខូចដល់ការជឿទុកចិត្តនៅក្នុងរដ្ឋបាលតុលាការ ហើយវាក៏ស្មើគ្នានឹងការគំរាមកំហែងទៅដល់ផលប្រយោជន៍នៃកិច្ចការរដ្ឋបាលដោយមិនលំអៀង និងដោយត្រឹមត្រូវរបស់តុលាការដែរ បើសិនជាចៅក្រមត្រូវបានគេប្តឹងជំទាស់ដោយផ្អែកលើការចោទប្រកាន់ថាលម្អៀង ដោយគ្មានមូលដ្ឋានត្រឹមត្រូវ និងគ្មានសំអាងអ្វីសម្រាប់គាំទ្រនោះ"[30]។ អាស្រ័យហេតុនេះ មេធាវីការពារក្តីមិនគ្រាន់តែត្រូវលើកភស្តុតាងឱ្យបានគ្រប់គ្រាន់យកមកបង្ហាញ ដើម្បីដាក់បន្ទុកជាធម្មតាសម្រាប់ភាគីអ្នកដាក់

---

[29] ឯកសារ ពិសេសរបស់ អបជ លេខ **PTC 02(3)5** សេចក្តីសម្រេចលើសំណើរបស់ អៀង សារី ដែលស្នើសុំឱ្យមានចំណាត់ការជាបន្ទាន់ទាក់ទងនឹងសេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជ្រៀតជ្រែកចំពោះឯករាជ្យភាពរបស់លោកចៅក្រមនៃអង្គបុរេជំនុំជម្រះ Katinka Lahuis និង Rowan Downing, ចុះថ្ងៃទី៣០ វិច្ឆិកា ២០០៩, កថាខណ្ឌទី ៦-៧។ សូមអានផងដែរ ករណីរឿងក្តីរបស់ *Olujić ទល់នឹងប្រទេស Latvia*, តុលាការ ECtHR ពាក្យសុំលេខ 22330/05, សាលក្រម, ចុះថ្ងៃទី៥ ឧសភា ២០០៩ ត្រង់កថាខណ្ឌទី ៥៧-៥៨។ ឯកសារលេខ **E55/4**, សេចក្តីសម្រេចលើពាក្យសុំរបស់ អៀង ធីរិទ្ធ នួន ជា និង អៀង សារី ដែលសុំប្តឹងជំទាស់លោកចៅក្រម និល ណុន, Silvia Cartwright, យ៉ា សុខន, Jean-Marc Lavergne និងលោកចៅក្រម ធូ មុនី, ចុះថ្ងៃទី២៣ មីនា ២០១១, ត្រង់កថាខណ្ឌទី១២។

[30] ឯកសារលេខ **E137/5** កំណត់សម្គាល់លេខ៣ *ពីខាងដើម* កថាខណ្ឌទី១៥។ សូមអានផងដែរ ឯកសារពិសេសរបស់ អបជ លេខ **PTC 02(3)5** កំណត់សម្គាល់លេខ ២៨ *ពីខាងដើម*, កថាខណ្ឌទី៧។

ពាក្យបណ្ដឹង ប៉ុន្តែថែមទាំងត្រូវផ្ដល់ភស្តុតាងឲ្យបានគ្រប់គ្រាន់ "ចៀសវៀងដាក់ការសន្មតខុសដែលលក្ខខណ្ឌតម្រូវមានកម្រិតខ្ពស់[31]។

១៨- "ការចោទប្រកាន់ណាមួយអំពីភាពលម្អៀង ត្រូវតែមានការគាំទ្រពីអង្គហេតុជាមូលដ្ឋាន"[32] "បញ្ហាផ្សេងៗ ដែលជាធម្មតាមិនគ្រប់គ្រាន់សម្រាប់ឲ្យប្ដឹងជំទាស់ចៅក្រមនោះ គឺមាន ការសង្ស័យ ជំនឿ សេចក្ដីសន្និដ្ឋាន យោបល់ ព្រមទាំងបញ្ហាផ្សេងទៀតស្រដៀងគ្នានេះដែលមិនមែនជាអង្គហេតុ"[33] "ការប្ដឹងជំទាស់ចៅក្រមមិនអាចធ្វើឡើងដោយការចោទប្រកាន់អំពីភាពមិនត្រឹមត្រូវផ្សេងៗដែលគ្មានអ្វីសម្រាប់គាំទ្រនោះបានឡើយ"[34]។

១៩- លើសពីនេះ ដោយសារតែមេធាវីការពារក្ដីបានយោងទៅលើសេចក្ដីសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូងធ្វើជាសញ្ញាបង្ហាញពីភាពលម្អៀង[35]នោះ ប្រការសំខាន់ គឺគួរកត់សម្គាល់ថា "នៅពេលការចោទប្រកាន់អំពីភាពលម្អៀងណាមួយត្រូវបានធ្វើឡើង ដោយផ្អែកលើមូលដ្ឋាននៃសេចក្ដីសម្រេចនានារបស់តុលាការ...អ្វីដែលត្រូវបង្ហាញឲ្យឃើញនោះគឺសេចក្ដីសម្រេចនោះត្រូវតែ ឬនឹងត្រូវបានយល់ឃើញដោយសមហេតុសមផលថា *ជាការនាំឲ្យមានការចេញសេចក្ដីសម្រេចជាមុន ប្រឆាំងនឹងអ្នកប្ដឹង* ហើយមិនទាក់ទងពិតប្រាកដទៅនឹងការអនុវត្តច្បាប់ឡើយ ដែលក្នុងនោះអាចនឹងមានលទ្ធភាពច្រើនជាងការបកស្រាយ ឬការវាយតម្លៃលើអង្គហេតុទាំងឡាយដែលពាក់ព័ន្ធ"[36]។

### ក) <u>មេធាវីការពារក្ដីខកខានមិនបានដាក់នូវបន្ទុករបស់ខ្លួន ដែលត្រូវបង្ហាញឲ្យឃើញថាមានភាពលម្អៀងជាក់ស្ដែង</u>

---

[31] ឯកសារលេខ **E55/4** កំណត់សម្គាល់លេខ ២៨ *ពីខាងដើម*, ត្រង់កថាខណ្ឌទី១២។

[32] ឯកសារពិសេសរបស់ អបជ លេខ **PTC 02(3)5** កំណត់សម្គាល់លេខ ២៨ *ពីខាងដើម*, កថាខណ្ឌទី៨។

[33] ដូចគ្នានឹងខាងលើ *ត្រង់កន្លែងដែល*, កថាខណ្ឌទី៨ (ការដកស្រង់សំដីផ្ទៃក្នុង ដែលត្រូវបានលុបចោល)។

[34] ឯកសារលេខ **E137/5** កំណត់សម្គាល់លេខ៣ *ពីខាងដើម*, កថាខណ្ឌទី២២។

[35] ឯកសារលេខ **E191**, កំណត់សម្គាល់លេខ១៥ *ពីខាងដើម*, កថាខណ្ឌទី១២-១៤។

[36] ឯកសារពិសេសរបស់ អបជ លេខ **PTC 02(3)5** កំណត់សម្គាល់លេខ ២៨ *ពីខាងដើម*, កថាខណ្ឌទី៩។ (ការសង្កត់ន័យបន្ថែមដោយដោយអក្សរទ្រេត)។

២០- មេធាវីការពារក្តីខកខានមិនបានបំពេញទៅតាមការសាកល្បងអំពីភាពលម្អៀងជាក់ស្តែង-"ការសាកល្បងជាអត្តនោម័ត"។ នៅក្នុងករណីរឿងក្តីរបស់ *Olujić* តុលាការសិទ្ធិមនុស្សអឺរ៉ុប(ECtHR) បានអះអាងជាថ្មីថា ការសាកល្បងនេះរួមមាន "ការខិតខំខ្នះខ្នែងដើម្បីបញ្ជាក់ការពិតអំពីពិរុទ្ធភាពរបស់បុគ្គល ឬអំពីផលប្រយោជន៍របស់បុគ្គលផ្ទាល់ជាចៅក្រមណាម្នាក់ នៅក្នុងករណីដោយឡែកណាមួយ"[37]។ មេធាវីការពារក្តីមិនបានបង្ហាញភ័ស្តុតាងអំពីពិរុទ្ធភាពរបស់បុគ្គល ឬអំពីផលប្រយោជន៍របស់លោកស្រីចៅក្រម Cartwright នៅក្នុងសំណុំរឿងលេខ០០២ឡើយ។ តាមពិត លោកស្រីចៅក្រម Cartwright បានជាប់នៅក្នុងលក្ខណៈដែលផ្ទុយទាំងស្រុងពីអ្វីដែលមេធាវីការពារក្តីបានខំប្រឹងដាក់ផ្លាកឲ្យ "ដោយគ្មានគិតអំពីការណែនាំដែលបានចេញដោយអង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូងស្តីពីអានុភាពគតិយុត្តនៃការប្រាស្រ័យទាក់ទង *ជាមួយភាគីតែម្ខាង* នោះឡើយ"[38]។ ផ្ទុយទៅវិញ ក្រុមរដ្ឋបាលមានការប៉ុនប៉ងប្រកបដោយសុទ្ធចិត្ត ដើម្បីធ្វើឲ្យការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលមានប្រសិទ្ធភាព។

២១- ទោះជាយ៉ាងណាក្តី សូម្បីតែនៅក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូង "ដាច់ខាតចំពោះសេចក្តីណែនាំច្បាស់លាស់របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ស្តីពីការបញ្ជូនពាក្យសុំត្រឡប់វិញក៏ដោយ" -ជាការសង្កត់ន័យ មិនមែនជាស្ថានភាពដែលតម្រូវឲ្យធ្វើភ្លាមៗនោះទេ - ការប្រព្រឹត្តិបែបនេះគឺវាមិនមែនជាភ័ស្តុតាងបង្ហាញពីភាពលម្អៀងនោះទេ បើសិនជា "អាចមានការពន្យល់ចំពោះចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានត្រៀមលក្ខណៈជាស្រេចផ្តល់អនុសាសន៍ដល់ខ្លួនឯង"[39]។ នៅទីនេះ ក្រៅពីការប្រកាន់យកដាច់ខាតស្តីពីការណែនាំដ៏ច្បាស់លាស់ស្តីពីការបញ្ជូនពាក្យសុំត្រឡប់វិញ សមាជិកទាំងឡាយនៃក្រុមរដ្ឋបាលបានប៉ុនប៉ង*អនុវត្តឲ្យបានសម្រេច*នូវការណែនាំដែលបានលើកជាអនុសាសន៍ដោយអង្គជំនុំជម្រះតុលាការកំពូល។ "អាចជាការពន្យល់"ដែលត្រៀមលក្ខណៈជាស្រេចក្នុងការលើកអនុសាសន៍ដល់ខ្លួនឯង" នោះគឺថាក្រោយពីការទទួលបានការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីអង្គប្រជុំរដ្ឋបាល រដ្ឋបាលបានធ្វើការពិភាក្សាអំពីថាតើត្រូវដំណើរការតាមបែបដូចម្តេច និង

[37] កំណត់សម្គាល់លេខ២៩ *ពីខាងដើម Olujić v. Latvia*, កថាខណ្ឌទី៥៧។

[38] ឯកសារលេខ **E191** កំណត់សម្គាល់លេខ ១៥ *ពីខាងដើម*, កថាខណ្ឌទី១០។

[39] រដ្ឋអាជ្ញា ទល់នឹង *Vidoje Blagojević និងគូកន.*, IT 02 60, សេចក្តីសម្រេចស្តីពីបណ្តឹងរបស់ Blagojević's អនុលោមតាមវិធាន ១៥ (ខ) ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌ១៤។

ក្នុងរយៈពេលពីរថ្ងៃបានធ្វើការសន្និដ្ឋានថា ប្រសើរបំផុតនោះគឺត្រូវតែបញ្ឈប់លែងឲ្យមានការប្រជុំបែបនេះទៀត។

## ខ) <u>មេធាវីការពារក្ដីខកខានមិនបានដាក់នូវបន្ទុករបស់ខ្លួន ដែលត្រូវបង្ហាញឲ្យឃើញអំពីរូបភាពនៃភាពលម្អៀង</u>

២២- ការបង្ហាញជារូបរាងនៃភាពលម្អៀង នឹងត្រូវបានបញ្ជាក់ការពិត បើសិនជា:

*(ក) ចៅក្រមណាម្នាក់ជាភាគីមួយនៅក្នុងករណីរឿងក្ដី ឬដែលមានផលប្រយោជន៍ខាងហិរញ្ញវត្ថុ ឬទ្រព្យសម្បត្តិណាមួយទាក់ទងនឹងលទ្ធផលនៃការសម្រេចលើរឿងក្ដីនោះ ឬសេចក្ដីសម្រេចរបស់ចៅក្រមនឹងធ្វើឲ្យមានការជួយជំរុញដល់មូលហេតុអ្វីមួយដែលខ្លួនមានពាក់ព័ន្ធនៅក្នុងនោះ ឬ (ខ) កាលៈទេសៈផ្សេងៗមុខជានឹងនាំឲ្យអ្នកសង្កេតការណ៍ដែលមានសុភវិនិច្ឆ័យទទួលបាននូវព័ត៌មានដោយត្រឹមត្រូវដើម្បីភ្ជាប់បានច្បាស់ពីភាពសមហេតុសមផលនៃភាពលម្អៀង*[40] ។

២៣- មេធាវីការពារក្ដីមិនបានលើកឡើងថា លោកស្រីចៅក្រម Cartwright បានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យណាមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យដូចដែលមានចែងនៅក្នុងផ្នែក (ក) ឡើយ ហេតុនេះដើម្បីឲ្យបានសម្រេចជោគជ័យ មេធាវីត្រូវតែដាក់បន្ទុករបស់ខ្លួនដើម្បីបង្ហាញឲ្យឃើញថា "កាលៈទេសៈនានាមុខជានឹងនាំឲ្យអ្នកសង្កេតការណ៍ដែលមានសុភវិនិច្ឆ័យ ទទួលបាននូវព័ត៌មានបានត្រឹមត្រូវ ដើម្បីយល់ឲ្យបានសមហេតុសមផលថាមានភាពលំអៀង[41]។ ("ការសាកល្បងរបស់អ្នកសង្កេតការណ៍ឯករាជ្យ")

---

[40] ឯកសារលេខ **E137/5** កំណត់សម្គាល់លេខ ៣ *ពីខាងដើម,* កថាខណ្ឌទី១៣។ ឯកសារលេខ **E171/2** សេចក្ដីសម្រេចលើពាក្យសុំប្ដឹងជំទាស់ចិត្តលោកស្រីចៅក្រម Silvia Cartwright, ចុះថ្ងៃទី៩ មីនា ២០១២, កថាខណ្ឌទី១២, ការដកស្រង់សំដី ឯកសារលេខ **E137/5**, កំណត់សម្គាល់លេខ ៣ *ពីខាងដើម,* កថាខណ្ឌទី១៣។

[41]ឯកសារលេខ **E55/4** កំណត់សម្គាល់លេខ ១៣ *ពីខាងដើម,* កថាខណ្ឌទី១១។ សូមអានផងដែរ ឯកសារលេខ **E137/2** ពាក្យសុំជាបន្ទាន់របស់ នួន ជា សុំប្ដឹងជំទាស់ចិត្តលោកស្រីចៅក្រម Cartwright, ចុះថ្ងៃទី២១ វិច្ឆិកា ២០១១។ ពាក្យសុំ, កថាខណ្ឌទី១៥ ។ ការសាកល្បងត្រូវបានគេពន្យល់ថា ជាចម្លើយតបមួយទៅនឹងសំណួរ, ដែល "ជនដែលមានសុភវិនិច្ឆ័យដែលមិនលំអៀង និងដែលត្រូវបានគេផ្ដល់ជូននូវព័ត៌មាន … ស្ដីពីអង្គហេតុដ៏ត្រឹមត្រូវយល់ឃើញដោយសមហេតុសមផលថា [លោកស្រីចៅក្រម Cartwright] មិនបាន ឬនឹងមិនប្រកាន់យកនូវគំនិតដែលមិនលំអៀង ដើម្បីយកមកធ្វើការវិនិច្ឆ័យលើរឿងក្ដីនេះឡើយ ហើយគំនិតនេះគឺជាគំនិតដែលបើកទូលាយសម្រាប់ការបញ្ចុះបញ្ចូលឲ្យជឿតាម

## 1. *ការរាសាកល្បងរបស់អ្នកសង្កេតការណ៍ប្រកបដោយសត្យានុម័ត*

២៤- ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សម្គាល់ជាដដែលៗថា អ្នកសង្កេតការណ៍មិនលំអៀង នៅក្នុងរឿងនេះគឺជា "ជនណាម្នាក់ដែលទទួលបានព័ត៌មាន ដោយបានដឹងអំពីកាលៈទេសៈពាក់ព័ន្ធទាំងអស់ ដែលរួមមាន ទំនៀមទម្លាប់ប្រពៃណីនៃសុច្ចរិតភាព និងភាពមិនលម្អៀងដែលជាផ្នែកបង្កើតបានជាប្រវត្តិដើមនេះផង ហើយក៏បានផ្តល់តម្លៃផងដែរអំពីអង្គហេតុដែលថា ភាពមិនលម្អៀងគឺជាភារកិច្ចមួយក្នុងចំណោមភារកិច្ចជាច្រើនដែលចៅក្រមទាំងឡាយត្រូវស្បថថានឹងប្រតិបត្តិតាម"[42]។

២៥- ការសន្មតជាមុនថាមិនមានភាពលម្អៀង ដែលអ្នកសង្កេតការណ៍មិនលម្អៀងត្រូវយកមកអនុវត្ត បន្ថែមពីលើការបង្កើតជាឧបសគ្គបន្ថែមមួយសម្រាប់ឲ្យភាគីណាប្តឹងសុំដិតចិត្តនោះ ក៏តម្រូវផងដែរឲ្យអ្នកសង្កេតការណ៍មិនលម្អៀងសន្មតថា សូម្បីតែនៅក្នុងស្ថានភាពដែលភាគីណាមួយអាចបង្ហាញឲ្យឃើញអំពីការចេញសេចក្តីសម្រេចជាមុនដោយចៅក្រម ទៅលើបញ្ហាណាមួយដែលទាក់ទងនឹងករណីរឿក្តី "ចៅក្រមទាំងឡាយនៃតុលាការអន្តរជាតិ "អាចធ្វើឲ្យគំនិតរបស់ខ្លួនផ្ទុយពីជំនឿផ្ទាល់របស់ខ្លួន ឬការចេញសេចក្តីសម្រេចជាមុន"[43]។ លោកស្រីចៅក្រម Cartwright គឺជា "អ្នកច្បាប់មួយរូបដែលមាន

ដោយភ័ស្តុតាង និងសារណាទាំងឡាយរបស់មេធាវី។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* *Furundžija*, សំណុំរឿងលេខ IT-95-17/1-A, សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២១ កក្កដា ២០០០, កថាខណ្ឌទី១៨៦, ១៩០, ១៩៧, ២០០, កថាខណ្ឌទី១៨៦, ការដកស្រង់សំដីរបស់ប្រធានាធិបតីនៃសាធារណៈរដ្ឋអាហ្វ្រិកខាងត្បូង និងជនដទៃទៀត *ទល់នឹង សហព័ន្ធបាល់ឱប និងរុយប៊ីនៃអាហ្វ្រិកខាងត្បូង និងជនដទៃទៀត*, សាលក្រមលើពាក្យសុំដកខ្លួនលេខ 1999 (7) BCLR 725 (CC), ចុះថ្ងៃទី៣ មិថុនា ១៩៩៩។

[42] ឯកសារលេខ **E171/2** កំណត់សម្គាល់លេខ ៣៦ *ពីខាងដើម*, កថាខណ្ឌទី១២ (ការលើកឡើងសំអាងផ្នែកក្នុងដែលត្រូវបានលុប)។ ឯកសារលេខ **E55/4** កំណត់សម្គាល់លេខ ២៨ *ពីខាងដើម*, កថាខណ្ឌទី១២, ការដកស្រង់សំដីក្នុងករណីរឿងរបស់ *Furundžija*, កំណត់សម្គាល់លេខ ៣៧ *ពីខាងដើម*, ត្រង់កថាខណ្ឌទី១៩០។

[43] ករណីរឿងក្តីរបស់*Furundžija*, កំណត់សម្គាល់លេខ ៣៧ *ពីខាងដើម*, កថាខណ្ឌទី១៩៧។ គោលការណ៍ស្តីពីការគោរពត្រឹមត្រូវទៅតាមលទ្ធភាពរបស់ចៅក្រមក្នុងការទុកដោយឡែកនូវការគិតពិចារណាផ្ទាល់ខ្លួននៅក្នុងការវិនិច្ឆ័យទៅលើករណីរឿងក្តីជាពិសេសណាមួយដែលត្រូវបានបង្ហាញភស្តុតាងដោយត្រឹមត្រូវ។ ឧទាហរណ៍ដូចជា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា ទោះបីជានៅក្នុងករណីដែលអាចមាន "ការបង្ហាញភស្តុតាង" ចៅក្រមដែលជំនុំជម្រះក្តីលើករណីរឿងណាមួយ "បានចូលរួមចំណែកនៅក្នុងការសម្រេចគោលដៅនិងទិសដៅនានា" របស់អង្គការមួយដែលបានធ្វើការតស៊ូមតិប្រឆាំងនឹងឧក្រិដ្ឋកម្មនានាមួយចំនួនដែលបានចោទប្រកាន់ថាត្រូវបានប្រព្រឹត្តដោយជនជាប់ចោទនៅក្នុងករណីរឿងនោះក៏ដោយក៏ចៅក្រមនឹងអាចមានលទ្ធភាពទុកមួយឡែកនូវការលំអៀងទៅរក នៅក្នុងករណីដោយឡែកណាមួយដែលស្ថិតនៅចំពោះមុខខ្លួនបានដែរ ហើយធ្វើការសម្រេចសេចក្តីលើរឿងក្តីនោះដោយមិនលំអៀង។ *ដូចគ្នានឹងខាងលើត្រង់កន្លែងដដែល*, ត្រង់កថាខណ្ឌទី២០០។

គុណវិឌ្ឍិខ្ពស់ និងមានបទពិសោធន៍ច្រើន” ដូចនេះអ្នកសង្កេតការណ៍ដែលមានសុភវិនិច្ឆ័យបានដឹងជាមុននូវកាលៈទេសៈដែលពាក់ព័ន្ធទាំងអស់ នឹងមិន“ធ្វើការសន្និដ្ឋានដោយសេរីៗ”ថា លោកស្រីអាចមានជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិខុសឆ្គង ដែលជាការរំលោភនឹងក្រមសីលធម៌ និងធ្វើល្មើសទៅនឹងកាតព្វកិច្ចនៃវិជ្ជាជីវៈរបស់លោកស្រី[44]។

២៦- “ពាក្យសុំមួយដែលជាការស្មាន ឬដែលផ្អែកទៅលើអារម្មណ៍ ឬការមន្ទិលសង្ស័យអំពីភាពលម្អៀងដោយជនជាប់ចោទតែប៉ុណ្ណោះ គឺវាមិនគ្រប់គ្រាន់ទេ”[45]។ មេធាវីការពារក្ដីត្រូវតែបង្ហាញក្នុងទម្រង់ជា “ការបង្ហាញភ័ស្តុតាងដែលរឹងមាំ”[46]ចំពោះចៅក្រមដែលកំពុងមានបញ្ហាដែលកំពុងតែប្រើប្រាស់នូវរាល់ជំនាញទាំងអស់របស់គាត់ នឹងមិនអាចមានលទ្ធភាពដើម្បីចេញនូវបុរេវិនិច្ឆ័យបានទេលើបញ្ហាដែលពាក់ព័ន្ធទៅនឹងសំណុំរឿងបានឡើយ ហើយធ្វើការវិនិច្ឆ័យលើសំណុំរឿងដែលនៅស្ថិតនៅចំពោះមុខខ្លួននោះបានត្រឹមត្រូវឡើយ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានព្រមានអំពីគ្រោះថ្នាក់នៃការងាយយល់ព្រមក្នុងការប្ដឹងជំទាស់ចៅក្រម៖

> *ទោះបីជាប្រការសំខាន់ដែលថា យុត្តិធម៌ត្រូវតែធ្វើឲ្យគេឃើញថាបានធ្វើក៏ដោយ ក៏ប្រការសំខាន់ដូចគ្នាដែរនោះគឺថា មន្ត្រីនានារបស់តុលាការដែលបំពេញភារកិច្ចរបស់ខ្លួនក្នុងការជំនុំជម្រះក្ដី មិនត្រូវចាំតែយល់ព្រមដោយងាយៗពេកចំពោះការស្នើសុំថាមានភាពលម្អៀង មិនលើកទឹកចិត្តដល់ភាគីនានាឲ្យជឿថា ក្នុងការប្ដឹងជំទាស់ចៅក្រមណាម្នាក់ រឿងក្ដីរបស់ពួកគេត្រូវបានធ្វើការជំនុំជម្រះដោយជនណាម្នាក់ ដែលគេគិតថាទំនងជានឹងធ្វើការសម្រេចលើរឿងក្ដីបានឈ្នះមកឲ្យខ្លួននោះឡើយ*[47]។

## 2. <u>*ការអនុវត្តសាកល្បងរបស់អ្នកសង្កេតការណ៍ប្រកបដោយសត្យានុម័ត*</u>

[44] ឯកសារលេខ **E55/4** កំណត់សម្គាល់លេខ ២៨ *ពីខាងដើម*, ត្រង់កថាខណ្ឌទី១៧។

[45] ឯកសារលេខ **E171/2** កំណត់សម្គាល់លេខ ៣៦ *ពីខាងដើម*, ត្រង់កថាខណ្ឌទី១៣ (ការដកស្រង់សំដីផ្ទៃក្នុងដែលត្រូវបានភ្លេច)។

[46] ករណីរឿងក្ដីរបស់ *Furundžija*, កំណត់សម្គាល់លេខ ៣៧ *ពីខាងដើម*, កថាខណ្ឌទី១៩៧។

[47] ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង *Zejnil Delalić នឹងគូរកន*, សំណុំរឿងលេខ IT-96-21-A, សាលក្រម, ចុះថ្ងៃទី២០ កុម្ភៈ ២០០១, កថាខណ្ឌទី៧០៧ (ការដកស្រង់សំដីត្រូវបានលុបចេញ)។

២៧- អ្នកសង្កេតការណ៍មិនលម្អៀងដោយសត្យានុម័ត នៅក្នុងស្ថានភាពនេះ មុខជាធ្លាប់យល់ដឹងយ៉ាងច្បាស់លាស់ហើយអំពី៖ (១) តួនាទីផ្សេងៗខាងផ្នែករដ្ឋបាលដែលលោកស្រីចៅក្រម Cartwright និងលោក Adrew Cayley សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបំពេញនៅ អវតក (២) ការប្រឆាំងរបស់មេធាវី និងមេធាវី នួន ជា កាលពីលើកមុនដែលជំទាស់ចំពោះការប្រជុំអំពីការងាររដ្ឋបាល និងចំពោះលទ្ធផលនៃដំណើរការនីតិវិធីទាំងនោះ (៣) ថានៅក្នុងកាលៈទេសៈធម្មតា រដ្ឋបាលគួរតែពិភាក្សាលើសេចក្ដីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលទាក់ទងទៅនឹងដំណើរការប្រព្រឹត្តទៅរបស់ស្ថាប័ននេះ ហើយ (៤) គំរូ និងការអនុវត្តរបស់មេធាវីការពារក្ដីដែលព្យាយាមដដែលៗ ដើម្បីប្ដឹងជំទាស់ចៅក្រមនៅ អវតក។

២៨- ថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា "ការប្រជុំការងាររដ្ឋបាលទាំងនេះនឹងមិនធ្វើឱ្យជនដែលត្រូវបានគេផ្ដល់ពត៌មានឱ្យយល់ឃើញថាមានភាពលម្អៀងនោះឡើយ ដោយសារមានការយល់ដឹងគ្រប់កាលៈទេសៈទាំងអស់ដែលទាក់ទង ជាពិសេស ដោយសារកិច្ចប្រជុំទាំងនេះមិនមានជាប់ទាក់ទងជាមួយនឹងបញ្ហាសំខាន់ៗនៅក្នុងរឿងក្ដីណាមួយដែលស្ថិតនៅចំពោះមុខ អវតក"[48]។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលបានថ្លែងថា ការប្រជុំទាំងនេះ "អាចនឹងបង្ហាញឱ្យឃើញថាមានការផ្ដល់សិទ្ធិដែលមិនមានភាពស្មើគ្នា ដែលសហព្រះរាជអាជ្ញាបានទទួលក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង"។ លទ្ធភាពនោះមិនត្រូវបានអនុវត្តបានសម្រេចប្រកបដោយប្រសិទ្ធភាពបានទេ នៅទីនេះ ជាពិសេស ដោយសារតែមានការពន្យល់ដូចតទៅនេះ៖ ការប្រាស្រ័យទាក់ទងបានកើតមានឡើងភ្លាមៗបន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលសម្រេចថាបញ្ឈប់ការប្រជុំបែបនេះ។

២៩- មេធាវីការពារក្ដីបានតវ៉ាថា អង្គជំនុំជម្រះសាលាដំបូងគួរយោងបណ្ដឹងសាទុក្ខមួយនៅក្នុងករណីរឿងក្ដីរបស់ *Kremera* នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន[49]។ ក្នុងករណីនេះ-- ជាករណីមួយគត់ដែលមេធាវីការពារក្ដីបានពឹងផ្អែកជាសំអាង-- គឺពាក់ព័ន្ធនឹង "ការរួមជាសមាគមយ៉ាងជិតស្និទ្ធ និង*រស់នៅក្នុងលំ*

---

[48] ឯកសារលេខ **E137/5** កំណត់សម្គាល់លេខ ២៦ *ពីខាងដើម*, កថាខណ្ឌទី២២។

[49] ឯកសារលេខ **E191** កំណត់សម្គាល់លេខ ១៥ *ពីខាងដើម*, កថាខណ្ឌទី១១។

*នៅផ្ទាន់ជាមួយអរបស់ចៅក្រម ជាមួយនឹងរដ្ឋអាជ្ញាមួយរូប*”[50]។ ការប្រឆាំងនឹងចៅក្រមនេះ ភាពទន់ខ្សោយនៃបណ្តឹងជិតចិត្តរបស់មេធាវីការពារក្តីបានធ្វើឲ្យឃើញកាន់តែច្បាស់។

## III. ការបង្ហាញណាមួយអំពីការប្រាស្រ័យទាក់ទងគ្នា មិនគួរត្រូវបានចេញដីកាបង្គាប់ដោយស្រាលៗនោះទេ

៣០- មេធាវីការពារក្តីបានស្នើដល់អង្គជំនុំជម្រះថា ដើម្បីផលប្រយោជន៍នៃយុត្តិធម៌ សុំឲ្យ“ចេញដីកាបង្គាប់” ដល់សហព្រះរាជអាជ្ញាអន្តរជាតិ និង“ណែនាំ”ដល់លោកស្រីចៅក្រម Cartwright ឲ្យធ្វើការបង្ហាញអំពី៖

> *រាល់ការប្រាស្រ័យទាក់ទងទាំងអស់* ជាមួយភាគីតែម្ខាង *រវាងពួកគេ ចាប់តាំងពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១មក ដែលរាប់បញ្ចូលទាំងលិខិតឆ្លើយឆ្លងគ្នាទាំងអស់ និងដែលទាក់ទងទៅនឹងការប្រជុំនានា* ជាមួយភាគីតែម្ខាង, *ចំនួននៃការប្រជុំដែលបានធ្វើឡើង, កាលបរិច្ឆេទនៃការប្រជុំ របៀបវារៈ និងរាល់វិធានការដែលបានចាត់ និងដែលអនុលោមទៅតាមការប្រជុំទាំងនេះ*[51] ។

៣១- គោលបំណងនៃការស្នើសុំឲ្យបង្ហាញដែលបានលើកឡើងនេះ គឺដើម្បី “កំណត់សម្រេចថាតើការដាក់សារណាបន្ថែមមួយចំនួន ជាការចាំបាច់ដែរ ឬទេ”[52]។ ការបង្ហាញខាងលើនេះដែលត្រូវបានស្នើសុំដោយមិនគិតអំពីការរកឃើញខាងអង្គហេតុ និងខាងអង្គច្បាប់លើខ្លឹមសារនៃសំណើប្តឹងជិតចិត្ត[53]។

---

[50] រឿងក្តីរបស់*Edouard Karamera និងគូរកន ទល់នឹង រដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-98-44-AR15*bis 2*, មូលហេតុដែលនាំឲ្យធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍អំពីបញ្ហាបន្ទាន់បង្ខំទាក់ទងទៅនឹងដំណើរការនីតិវិធីដោយចៅក្រមជំនួសមួយរូប និងលើញត្តិរបស់ Nzirorera ដែលស្នើសុំអនុញ្ញាតពិនិត្យពិចារណាលើឯកសារថ្មី, ចុះថ្ងៃទី២២ តុលា ២០០៤, កថាខណ្ឌទី៦៧ (ដែលសង្កត់ន័យបន្ថែមដោយអក្សរទ្រេត)។

[51]ឯកសារលេខ **E191** កំណត់សម្គាល់លេខ ១៥ *ខាងដើម*, កថាខណ្ឌទី២២ [សំណើសុំសំណងជួសជុល, ចំណុច(គ)]។

[52] *ដូចគ្នានឹងខាងលើត្រង់កន្លែងដដែល* ទំព័រ១។ សូមអានផងដែរ កថាខណ្ឌទី២២ (ដែលប្រើប្រាស់ពាក្យពេចន៍ដែលកាន់តែមានលក្ខណៈបណ្តោះអាសន្នឡើង: “តើការដាក់សារណាបន្ថែមអាចមានភាពចាំបាច់ដែរ ឬទេ”។

[53] *ដូចគ្នានឹងខាងលើត្រង់កន្លែងដដែល* កថាខណ្ឌទី២០។

៣២- សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណើសុំឱ្យបង្ហាញនេះគួរត្រូវបានបដិសេធចោល ដោយផ្អែកលើហេតុផលសំខាន់ពីរយ៉ាងគឺ៖ (១) សំណើសុំនេះ គឺគ្រាន់តែលើកយកមកធ្វើការតវ៉ាសាជាថ្មីលើសំណើសុំកាលពីមុនដែលត្រូវបានបដិសេធទាំងនៅអង្គជំនុំជម្រះសាលាដំបូង និងនៅពេលប្តឹងឧទ្ធរណ៍[54] និង (២) ដីកាបង្គាប់ឱ្យធ្វើការបង្ហាញដែលបានស្នើសុំ (ឬការណែនាំ) គឺមិនមានមូលដ្ឋានខាងផ្លូវច្បាប់ណាមួយនៅក្រោមវិធាន៣៤នៃវិធានផ្ទៃក្នុង ឬនៅក្នុងទម្លាប់អនុវត្តដែលទាក់ទងណាមួយឡើយ[55]។

៣៣- សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណើសុំឱ្យធ្វើការបង្ហាញនេះគឺស្មើទៅនឹងការព្យាយាម ដើម្បីបិទបាំងការប៉ុនប៉ងលើកយកមកតវ៉ាសាជាថ្មីនូវខ្លឹមសារនៃសំណើសុំកាលពីលើកដំបូង (ឯកសារលេខ 137/3) ដែលក្នុងនោះរួមមានពាក្យសុំឱ្យបំពេញកិច្ចស៊ើបសួរមួយ អនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង ដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងពិនិត្យពិចារណាតាមផ្លូវច្បាប់ និងដែលត្រូវបានបដិសេធលើខ្លឹមសារដោយអង្គជំនុំជម្រះតុលាការកំពូល[56]។ ជំហររបស់សហព្រះរាជអាជ្ញា នៅទីនេះ គឺត្រូវបានគូសបញ្ជាក់ដោយអង្គហេតុចំនួនបីគឺ៖ ទីមួយ៖ មេធាវីការពារក្តីបានបញ្ជាក់យ៉ាងច្បាស់ពីអត្ថសញ្ញាណនៃសំណើសុំលើកដំបូងថា "មានភាពចាំបាច់ ត្រូវឱ្យធ្វើការបង្ហាញទាំងស្រុង" រាល់ការប្រាស្រ័យទាក់ទងទាំងអស់ *ជាមួយភាគីតែម្ខាង* រវាងសហព្រះរាជអាជ្ញាអន្តរជាតិលោក Andrew Cayley, លោកស្រីចៅក្រម Cartwright និងអ្នកផ្សេងទៀត"[57] ទីពីរ៖ កាលបរិច្ឆេទដែលចាប់តាំងពីពេលនោះមក មេធាវីការពារក្តីបានទាមទារសុំឱ្យធ្វើការបង្ហាញអំពីការប្រាស្រ័យទាក់ទងនានា ត្រូវបានបញ្ជាក់អត្តសញ្ញាណយ៉ាងច្បាស់ ដូចជា "កាលបរិច្ឆេទនៃសំណើសុំបំពេញកិច្ចស៊ើបសួរ"[58] និង ទីបី៖ "ព័ត៌មានដែលស្នើសុំ"របស់មេធាវីការពារក្តី ក្នុងសំណើសុំលើកដំបូងរបស់ខ្លួនមានលក្ខណៈស្រដៀងគ្នាទៅនឹងសំណើសុំឱ្យធ្វើការបង្ហាញភ្លាមៗ៖

> *(ក) បញ្ជីមួយនៃការប្រជុំទាំងអស់ ដែលមានលោក Andrew Cayley និងលោកស្រីចៅក្រម Cartwright ចូលរួមនៅក្នុងការប្រាស្រ័យទាក់ទង* ជាមួយភាគីតែម្ខាង *ដោយមិនគិតអំពីថាតើការប្រជុំទាំងនេះមានការចូលរួមពីជនដទៃទៀតដែរ ឬក៏អត់នោះ*

---

[54] ឯកសារលេខ E137/5 កំណត់សម្គាល់លេខ ៣ *ពីខាងដើម*។ ឯកសារលេខ E137/5/1/3 កំណត់សម្គាល់លេខ ៧។

[55] ឯកសារពិសេសរបស់ អបជ លេខ Special PTC 02(3)5 កំណត់សម្គាល់លេខ ២៨ *ពីខាងដើម*, កថាខណ្ឌទី១០។

[56] ឯកសារលេខ E137/5/1/3 កំណត់សម្គាល់លេខ ៧ កថាខណ្ឌទី២៣។

[57] ឯកសារលេខ E137/3 កំណត់សម្គាល់លេខ១ *ខាងដើម*, ទំព័រ១ និងកថាខណ្ឌទី២៣ [សង្កត់ន័យបន្ថែមដោយអក្សរទ្រេត]

[58] ឯកសារលេខ E191 កំណត់សម្គាល់លេខ ១៥ *ខាងដើម*, កថាខណ្ឌទី២០។

*នៅពេលដែលការពិភាក្សាទាំងនោះពាក់ព័ន្ធនឹងសំណុំរឿងលេខ០០២ ទោះដោយផ្ទាល់ ឬដោយប្រយោលក្តី (ខ) រាល់អង្គហេតុដែលពាក់ព័ន្ធ និងខ្លឹមសារលម្អិតទាំងអស់ដែលទាក់ទងនឹងការប្រជុំ* ជាមួយភាគីតែម្ខាង *ទាំងនេះ ដែលរួមមាន តែការកម្រិតកំណត់ត្រឹមរបៀបវារៈ និង/ឬ កំណត់ហេតុ (ទោះបីគ្រាន់តែជាក្រៅផ្លូវការ និង/ឬ ជាកំណត់ត្រាដែលបានសរសេរដោយដៃនោះក៏ដោយ)*[59]។

៣៤- លើសពីនេះទៅទៀត វិធាន៣៤នៃវិធានផ្ទៃក្នុងមិនបានបញ្ញត្តិឲ្យមានការស៊ើបអង្កេត និងអំណាចក្នុងការស៊ើបអង្កេតទេ និងមិនបានចែងច្បាស់ពីមូលដ្ឋានខាងផ្លូវច្បាប់សម្រាប់ការចេញសេចក្តីបង្គាប់ដើម្បីឲ្យធ្វើការបង្ហាញ(ឬការណែនាំ)ដែលប្រឆាំងនឹងចៅក្រមជំនុំជម្រះ ឬ/នឹងសហព្រះរាជអាជ្ញាឡើយ។ មេធាវីការពារក្តីព្រមទទួលស្គាល់រួចហើយអំពីករណីនេះ ដោយពឹងផ្អែកសំណើលើកដំបូងរបស់ខ្លួនទៅលើអំណាចមូលដ្ឋានក្នុងការស៊ើបអង្កេតរបស់អង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន៩១, ៣៥, និង៩៣ នៃវិធានផ្ទៃក្នុងដែលអាន "ភ្ជាប់ជាមួយគ្នា" ដោយមិនមានយោងទៅលើវិធាន៣៤នោះឡើយ[60]។ ដូចដែលអង្គបុរេជំនុំជម្រះបានធ្វើសេចក្តីសង្កេតរួចមកហើយ ក្នុងពេលសម្រេចបញ្ចប់នូវសំណើកាលពីលើកមុនរបស់មេធាវីការពារក្តី អៀង សារី អនុលោមតាមវិធាន៣៤ "ដែលមិនអាចឲ្យទទួលយកបាន និងគ្មានមូលដ្ឋានត្រឹមត្រូវ"[61] ថ្លែងថា៖

*សំណាងជួសជុលដែលបានគ្រោងទុកនៅក្នុងវិធាន៣៤ នៃវិធានផ្ទៃក្នុង [...]គឺការប្តឹងដិតចិត្តចៅក្រម ដែលការណ៍នេះតម្រូវឲ្យភាគីអ្នកដាក់ពាក្យប្តឹងត្រូវបង្ហាញភស្តុតាងឲ្យឃើញថា ចៅក្រមដែលមានបញ្ហានោះ មានភាពលម្អៀងជាសត្យានុម័ត។ សេចក្តីសង្កេតនេះបានបន្តថា [អង្គជំនុំជម្រះ] មិនតម្រូវឲ្យចាត់វិធានការណ៍ទេ បើសិនបន្ទុកនេះមិនត្រូវដាក់។ អនុលោមតាមវិធានផ្ទៃក្នុង អង្គជំនុំជម្រះគ្មានយុត្តាធិការក្នុងការទទួលបន្ទុកធ្វើ [...]ការស៊ើបសួរជាទូទៅនោះទេ ហើយក៏គ្មានអំណាចក្នុងការចេញដីកាបង្គាប់ឲ្យធ្វើការស៊ើបសួរលើការចោទប្រកាន់ណាមួយអំពីភាពលម្អៀង ឬអនាគតិដែលគ្មានភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រនោះដែរ។ ដើម្បីរកឲ្យឃើញផ្សេងពីនេះ អាចជាការដាក់បន្ទុកខុស*

[59] ការប្រៀបធៀបឯកសារលេខ **E137/3** កំណត់សម្គាល់លេខ ១ *ខាងដើម*, ទំព័រ១ និងឯកសារលេខ **E191** កំណត់សម្គាល់លេខ ១៥ *ខាងដើម*, កថាខណ្ឌទី២២(គ)។

[60] ឯកសារលេខ **E137/3** កំណត់សម្គាល់លេខ ១ *ខាងដើម*, ទំព័រ១ និង កថាខណ្ឌទី២។

[61] ឯកសារពិសេសរបស់ អបជ លេខ **Special PTC 02(3)5** កំណត់សម្គាល់លេខ ២៨ *ពីខាងដើម*, កថាខណ្ឌទី១៥។

*ក្នុងការបង្ហាញភស្តុតាងទៅលើអ្នកដាក់ពាក្យប្តឹង ដែលចាំបាច់ត្រូវតែជំទាស់ចំពោះការសន្មតជាមុនថាមិនមានភាពលម្អៀង*[62]។

៣៥- សំណើសុំលើកដំបូងត្រូវបានពិនិត្យពិចារណាដោយត្រឹមត្រូវ និងត្រូវបានបដិសេធដោយអង្គជំនុំជម្រះតុលាការកំពូល[63]។ ឥឡូវនេះ ដូចដែលមេធាវីការពារក្តីបានដឹងយ៉ាងពេញលេញអស់ហើយតាមរយៈការសម្រេចលើសារណាចំនួនពីរក្នុងចំណោមសារណារបស់ខ្លួនពីមុនៗ "វិធាន៣៥នៃវិធានផ្ទៃក្នុង គឺមិនមែនជាយន្តការសមស្របសម្រាប់ផ្តត់ផ្គង់នូវភស្តុតាង ដើម្បីគាំទ្រចំពោះបណ្តឹងជិតចិត្តនោះឡើយ"[64]។ វិធាន៣៤ក៏មិនមែនចែងដែរ។ ដូចដែលបានលើកឡើងសម្អាងខាងលើ អង្គបុរេជំនុំជម្រះបានរកឃើញថា អង្គជំនុំជម្រះណាមួយមិនអាចទទួលបន្ទុកធ្វើការស៊ើបសួរជាទូទៅបានទេ ឬតាមការពិតទៅ ការស៊ើបសួរណាមួយអនុលោមតាមវិធានផ្ទៃក្នុងដែលទាក់ទងទៅនឹងសីលធម៌របស់ចៅក្រមណាម្នាក់ ជាបឋមគឺ លុះត្រាតែអ្នកដាក់ពាក្យប្តឹងបានដាក់បន្ទុកខុស នូវ"ការដាក់បន្ទុកភស្តុតាងធ្ងន់របស់ខ្លួន"[65]។

៣៦- ការបកស្រាយនូវវិធាន៣៤នេះ ត្រូវបានគាំទ្រដោយវិធាននៃនីតិវិធីដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិ ដែលអង្គជំនុំជម្រះអាចយោងទៅលើការបកស្រាយនោះ អនុលោមមាត្រា៣៣ថ្មីនៃច្បាប់អវតក។ នៅក្នុងករណីរឿងក្តីរបស់ *Prlić និងគូរកន* លោក Michel Karnavas (ជំនួសឲ្យ *Jadranko Prlić*) បានប្តឹងជិតចិត្តចៅក្រម Árpánd Prandler នៃអង្គជំនុំជម្រះទី IIIដោយផ្អែកលើមូលដ្ឋាននៃការចោទប្រកាន់អំពីភាពលម្អៀងដែលកើតចេញមកពី "ការចូលរួមជាសមាគម"របស់គាត់ជាមួយនឹងមន្ត្រីម្នាក់ទទួលបន្ទុកកិច្ចការស៊ីវិលរបស់អង្គការសហប្រជាជាតិ[66]។ បន្ទាប់ពីដំណើរការរឿងក្តីអស់រយៈពេលជាយូរ នៅចុងបញ្ចប់ប្រធានតុលាការ ICTY គឺចៅក្រម Robinson

---

[62] ឯកសារពិសេសរបស់ អបជ លេខ **Special PTC 02(3)5** កំណត់សម្គាល់លេខ ២៨ *ពីខាងដើម*,កថាខណ្ឌទី១០។[សង្កត់ន័យបន្ថែមដោយអក្សរទ្រេត]

[63] **E137/5/1/3** កំណត់សម្គាល់លេខ ៧ *ខាងដើម*, កថាខណ្ឌទី២៣។

[64] ឯកសារលេខ **E137/5** កំណត់សម្គាល់លេខ៣ *ខាងដើម*, កថាខណ្ឌទី១៤ ។ ដែលលើកសម្អាងដោយធ្វើការប្រៀបធៀបទៅនឹងសេចក្តីសម្រេច លើពាក្យសុំរបស់ អៀង សារី ដែលសុំប្តឹងជិតចិត្តលោកចៅក្រម Marcel Lemonde អនុលោមតាមវិធាន៣៥ ចុះថ្ងៃទី២៣ មីនា ២០១០។

[65] ឯកសារពិសេសរបស់ អបជ លេខ **PTC 02(3)5** កំណត់សម្គាល់លេខ ២៨ *ពីខាងដើម*, កថាខណ្ឌទី១០ ។

[66] *រដ្ឋអាជ្ញា ទល់នឹង Jadranko Prlić និងគូកន.*, IT-04-74-T, ញត្តិរបស់ Jadranko Prlić ប្តឹងជិតចិត្តចៅក្រម Árpánd Prandler, ៣០ សីហា ២០១០។

បានរកឃើញថាមេធាវីការពារក្តី *Prlić* "ខកខានមិនបានបង្ហាញភ័ស្តុតាងណាមួយចំពោះការទាមទាររបស់ខ្លួនទេ" ហើយបានសម្រេចថាសំណើជិតចិត្តនោះ "គ្មានខ្លឹមសារអ្វីបន្តិចសោះឡើយ" ព្រមទាំងមិនបានធ្វើឱ្យគណៈកម្មការទទួលបន្ទុកបណ្តឹងជិតចិត្តជឿទុកចិត្ត[67]។ ជាផ្នែកនៃយុទ្ធសាស្ត្រផ្លូវច្បាប់ដែលគាត់បានជ្រើសរើស លោក Karnavas បានស្នើឱ្យបង្ហាញនូវ "ការប្រាស្រ័យទាក់ទង*តែភាគីម្ខាង" ដែលបានចោទប្រកាន់* រវាងចៅក្រម Prandler និងប្រធានអង្គជំនុំជម្រះ ក្នុងរឿងក្តី *Prlić*, គឺចៅក្រម Jean-Claude Antonetti ដោយទាមទារថាការមិនបង្ហាញ គឺជាការរំលោភសិទ្ធិរបស់កូនក្តីរបស់ខ្លួន ក្នុងការទទួលបានសវនាការមួយដែលត្រឹមត្រូវ[68]។ មិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលនោះទេដែលថា សំណើសុំការបង្ហាញនេះត្រូវបានបដិសេធ ដោយចៅក្រមប្រធានអង្គជំនុំជម្រះ III គឺចៅក្រម O-Gon Kwon។ ចៅក្រម Kwon ដោយឈរលើស្មារតីនៃការទទួលខុសត្រូវផ្នែករដ្ឋបាលរបស់គាត់ក្នុងនាមជាប្រធានចៅក្រមជំនុំជម្រះ ក៏ធ្លាប់បានធ្វើការប្រាស្រ័យទាក់ទងជាឯកជនជាមួយចៅក្រម Prandler ពាក់ព័ន្ធនឹងសំណើជិតចិត្តមិនទាន់បានសម្រេចនេះ។ តាមទស្សនៈទូទៅរបស់ប្រធានរូបនេះ សេចក្តីសម្រេចរបស់គាត់ក្នុងការបដិសេធលើសំណើសុំការបង្ហាញ ត្រូវបានតម្កល់ទុកជាការអនុវត្តយ៉ាងពេញលេញ និងប្រកបដោយសមត្ថកិច្ចតាមឆន្ទានុសិទ្ធិរបស់តុលាការ[69]។

៣៧- នៅចំពោះមុខ អ.វ.ត.ក ព្រំដែននៃសេចក្តីសម្រេចក្នុងរឿងក្តី *Prlić* និងគូកន., ត្រូវបានអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូងការសម្រេចលើសំណើទីមួយ ទុកជាប្រភពច្បាប់ដែលពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទង *តែភាគីម្ខាង* ដែលមិនទាក់ទងនឹង "សារធាតុនៃកិច្ចដំណើរការនីតិវិធី" នៅក្នុងរឿងក្តីដែលបានលើកឡើង[70]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថាព្រំដែននៃសេចក្តីសម្រេចនេះជួយគាំទ្របន្ថែមដល់គោលជំហរដែលថា ការបង្ហាញនូវការប្រាស្រ័យទាក់ទងមិនគួរត្រូវបានគេយល់ស្របថា ជាមធ្យោបាយមួយសម្រាប់ភាគីដែលប្តឹងជិតចិត្ត ដើម្បី *ផ្តល់នូវ* ភ័ស្តុតាងនៅក្នុងពេលនៃកិច្ចដំណើរការនីតិវិធីនៃការប្តឹងជិតចិត្តនោះឡើយ ជាពិសេស នៅក្នុងបរិបទនៃការចោទប្រកាន់អំពីការប្រព្រឹត្តិខុសក្រមសីលធម៌ដែលធ្លាប់បានសាកល្បងតាមផ្លូវច្បាប់ និងបានរកឃើញថាគ្មានខ្លឹមសារសោះ[71]។

---

[67] *រដ្ឋអាជ្ញា ទល់នឹង Jadranko Prlić និងគូកន.*, IT-04-74-T, សេចក្តីសម្រេចរបស់ប្រធានលើញត្តិរបស់ Jadranko Prlić ប្តឹងជិតចិត្តចៅក្រម Árpánd Prandler, ៤ តុលា ២០១០។

[68] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី៤។

[69] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី១៣។

[70] **E137/5** *កំណត់សម្គាល់ខាងដើម* លេខ៣, កថាខណ្ឌទី១៧។

[71] *ដដែលដូចខាងលើ,* និងឯកសារលេខ **E137/5/1/3** *កំណត់សម្គាល់ខាងដើម* លេខ៧។

៣៨- ដូចអង្គជំនុំជម្រះតុលាការកំពូលបានធ្វើការកត់សម្គាល់នៅពេលថ្មីៗនេះថា៖ "គេគ្មានយុត្តាធិការដែលដាក់បញ្ញត្តិឲ្យអង្គជំនុំជម្រះណាមួយនៃ អ.វ.ត.ក ត្រូវដោះស្រាយលើបញ្ហាវិន័យទាក់ទងនឹងចៅក្រមណាម្នាក់នៃ អ.វ.ត.ក ឲ្យលើសពីអ្វីដែលមានចែងនៅក្នុងវិធាន៣៤"[72]ឡើយ។ នៅខណៈដែល "ចៅក្រមណាម្នាក់ យ៉ាងហោចណាស់ បើតាមគោលការណ៍ ត្រូវស្ថិតនៅក្រោមយុត្តាធិការនៃវិធាន ៣៥" ការណ៍នេះតម្រូវថា "ទង្វើដែលរងនូវការចោទប្រកាន់នោះត្រូវតែឡើងដល់កម្រិតនៃការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការ ក្រោមនិយមន័យនៃវិធានទាំងនេះ"[73]។ អាស្រ័យហេតុនេះ បើលើសពីវិធានទាំងពីរនេះ "ការណែនាំ" ដូចបានស្នើឡើងឲ្យចៅក្រម Cartwright និងការបង្គាប់ឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ Cayley បង្ហាញការអំពីប្រាស្រ័យទាក់ទងរបស់គាត់នោះ គឺច្បាស់ណាស់ថាវាមានកង្វះខាតខាងច្បាប់ជាមូលដ្ឋាន។

៣៩- បើសិនជាអង្គជំនុំជម្រះនេះត្រូវពិចារណា ដើម្បីបង្គាប់ឲ្យមានការបង្ហាញអំពីការប្រាស្រ័យទាក់ទងដោយផ្អែកទៅលើអំណាចភ្ជាប់ ឬអំណាចទូទៅ នោះសហព្រះរាជអាជ្ញាសន្និដ្ឋានថា នឹងមានឧបសគ្គដ៏ធំធេងជាមិនខាន ជាពិសេស គោលបំណងនៃការស្នើឲ្យបង្ហាញនោះ គឺគ្រាន់តែដើម្បីកួរសមុទ្រឲ្យមាន "ការដាក់សារណាមានសក្តានុពលបន្ថែម"តែប៉ុណ្ណោះ[74]។ គោលជំហររបស់សហព្រះរាជអាជ្ញាត្រូវបានពង្រឹងបន្ថែមតាមការលាតត្រដាងនូវភាពខុសគ្នាតែមួយគត់ រវាងសំណើទីមួយ និងសំណើសុំឲ្យដាក់បង្ហាញនេះ : ការលុបបំបាត់ទំនាក់ទំនងណាមួយរវាងសម្ភារៈដែលបានស្នើសុំ និងសំណុំរឿង ០០២[75]។

### IV. សំណើសុំនូវ "ដំណោះស្រាយតាមជម្រើសផ្សេង" គួរត្រូវបានបដិសេធចោល

៤០- មេធាវីការពារក្តីស្នើបន្ថែមថា អង្គជំនុំជម្រះ "បង្គាប់" ឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ និង "ណែនាំ" ឲ្យចៅក្រម Cartwright:

---

[72] **E137/5/1/3** *កំណត់សម្គាល់ខាងដើម* លេខ៧, កថាខណ្ឌទី១៣។

[73] **E137/5/1/3** *កំណត់សម្គាល់ខាងដើម* លេខ៧, កថាខណ្ឌទី១៤។

[74] **E191** *កំណត់សម្គាល់ខាងដើម* លេខ១៥, កថាខណ្ឌទី២២។

[75] ប្រៀបធៀប **E137/3** *កំណត់សម្គាល់ខាងដើម* លេខ១, ទំព័រទី១ ជាមួយ **E191** *កំណត់សម្គាល់ខាងដើម* លេខ១៥, កថាខណ្ឌទី២២(គ)។

*បញ្ឈប់ និងឈប់ធ្វើការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាង និងគ្រប់ការប្រាស្រ័យទាក់ទងនាពេលអនាគតដែលពាក់ព័ន្ធនៅ អ.វ.ត.ក ទាំងអស់ រវាងពួកគាត់ ត្រូវតែចម្លងជូនសមាជិកណាម្នាក់របស់ DSS ឬ ក្រុមមេធាវីការពារក្ដី, តាមការសមស្រប*[76]។

៤១- ដូចមានចែងនៅក្នុងវាក្យខណ្ឌ II(ខ)ខាងលើ ការប្រាស្រ័យទាក់ទងនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ មិនអាចត្រូវបានគេពិចារណាថា ជាការប្រាស្រ័យទាក់ទង*តែភាគីម្ខាង*ឡើយ ដោយហេតុថា វាពាក់ព័ន្ធទៅនឹងបញ្ហាដែលមិនពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធី អ.វ.ត.ក នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះសាលាដំបូង។ ការជួបប្រជុំ និងការប្រាស្រ័យទាក់ទងពីដើមដំបូងពាក់ព័ន្ធនឹងបញ្ហាទាំងឡាយមានលក្ខណៈផ្ទៃក្នុងចំពោះ UNAKRT ដែលមេធាវីការពារក្ដីមិនអាចជា "ភាគី" ឲ្យបានត្រឹមត្រូវឡើយ។ លោក Rosandhaug ដែលតួនាទីរបស់លោកត្រូវអព្យាក្រឹតរវាងគូភាគីចំពោះកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក បានបញ្ជាក់អះអាងថា ការជួបប្រជុំ និងការប្រាស្រ័យទាក់ទងពីដើមដំបូងបានលើកឡើងពី "បញ្ហាផ្នែកប្រតិបត្តិការទូលំទូលាយដែលប៉ះពាល់ខាង<u>ផ្នែកអន្តរជាតិនៃ អ.វ.ត.ក</u>"[77]។ ដូចអង្គជំនុំជម្រះសាលាដំបូងខ្លួនឯងផ្ទាល់បានរៀបរាប់ដែរថា កិច្ចប្រជុំទាំងនេះពាក់ព័ន្ធនឹង "បញ្ហារដ្ឋបាលជាក់លាក់" ដែលជាក់ទាកទង<u>ផ្ទាល់មុខ</u> តែខាងផ្នែកអង្គការសហប្រជាជាតិនៃតុលាការ"[78]ប៉ុណ្ណោះ។ មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ជាក់បំភ្លឺអំពី "កិច្ចប្រជុំគ្រប់គ្រង" ទាំងនេះដែរថា "ពីដើមធ្លាប់បានជួបប្រជុំតាមសំណើរបស់ការិយាល័យទទួលបន្ទុកកិច្ចការច្បាប់ [របស់អង្គការសហប្រជាជាតិ] និងថាការប្រាស្រ័យទំនាក់ទំនងថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ បង្កើតបានជាផ្នែកនៃ "កិច្ចពិភាក្សាដោយសង្ខេប" មួយ ដែលនាំដល់ការសម្រេចចិត្តមួយ មិនបន្តកិច្ចប្រជុំទៀតទេ ទៅតាមស្មារតីនៃការជូនយោបល់របស់អង្គជំនុំជម្រះតុលាការកំពូល[79]។

៤២- ជាការបន្ថែម ដូចបានកត់សម្គាល់ពីខាងលើ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់រួចហើយអំពីវិសាលភាពនៃការដាក់វិន័យប្រឆាំងនឹងចៅក្រម ទៅតាមអនុវិធានទាំងបួននៃវិធាន៣៤ និងវិធាន៣៥ បើសិនជាបានបំពេញតាមលក្ខខណ្ឌកំណត់និមួយៗខាងផ្នែកភ័ស្តុតាង[80]។ ដូច្នេះ បើលើសពីវិធានទាំង

---

[76] **E191** *កំណត់សម្គាល់ខាងដើម* លេខ១៥, កថាខណ្ឌទី១៧។

[77] **E137/5** *កំណត់សម្គាល់ខាងដើម* លេខ៣, កថាខណ្ឌទី២០ [សង្កត់ន័យត្រង់កន្លែងគូសបន្ទាត់ពីក្រោម]។

[78] **E137/5** *ដដែលដូចខាងលើ* [សង្កត់ន័យត្រង់កន្លែងគូសបន្ទាត់ពីក្រោម]។

[79] **E191.1.3** អ៊ីម៉ែលពីលោកស្រី Susan Lamb ជូនមេធាវីការពារក្ដី អៀង សារី, ២០ មេសា ២០១២ និងអ៊ីម៉ែលពីមេធាវីការពារក្ដី អៀង សារី ជូនគូភាគី, ២០ មេសា ២០១២។

[80] សូមមើលខាងលើ, កថាខណ្ឌទី៣៧។

ពីរនេះ “ការណែនាំ” ដែលស្នើឲ្យចៅក្រម Cartwright “បញ្ឈប់ និងឈប់” ពីការប្រាស្រ័យទំនាក់ទំនង គឺជាកង្វះខាតខាងមូលដ្ឋានច្បាប់យ៉ាងជាក់ស្តែង”។

## V. សេចក្តីសន្និដ្ឋានចុងក្រោយ និងដំណោះស្រាយដែលស្នើឡើង

៤៣- ដូចមានចែងពីខាងលើ បណ្តឹង និងសំណើសុំរបស់មេធាវីការពារក្តី គឺគ្មានមូលដ្ឋានយ៉ាងច្បាស់ក្រឡែតទាំងនៅក្នុងអង្គច្បាប់ និងអង្គហេតុ។ លើសពីនេះ សំណើជំទាស់នេះ មិនអាចត្រូវគេមើលឃើញដាច់ដោយឡែកពីការប៉ុនប៉ងជាច្រើនលើកច្រើនសាររបស់ក្រុមមេធាវីការពារក្តី ដើម្បីទទួលបានការជំទាស់ចៅក្រមនានាក្នុងសំណុំរឿង០០២ ដែលក្នុងសំណើទាំងនោះមិនត្រូវបានសម្រេចថា មានភស្តុតាងបង្ហាញគ្រប់គ្រាន់នោះឡើយ។ យ៉ាងហោចណាស់ នេះជាបណ្តឹងទីដប់របស់ក្រុមមេធាវីការពារក្តីដែលប្តឹងជំទាស់ចៅក្រមទាក់ទងនឹងសំណុំរឿង០០២។ ហើយនេះជាបណ្តឹងជំទាស់ទីប្រាំរបស់មេធាវីការពារក្តី អៀង សារី។ លោកស្រីចៅក្រម Cartwright បានក្លាយជាកម្មវត្ថុនៃបណ្តឹងជំទាស់ចំនួនប្រាំមួយរបស់មេធាវីការពារក្តី ទោះតែម្នាក់ឯង ឬជាផ្នែកនៃក្រុមមួយ ហើយពាក់កណ្តាលនៃចំនួននេះ ត្រូវបានដាក់ដោយមេធាវីការពារក្តី អៀង សារី។ បណ្តឹងនិមួយៗ ត្រូវបានបដិសេធចោល។

៤៤- អាស្រ័យដោយមូលហេតុដូចបានរៀបរាប់ពីខាងលើ សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះសាលាដំបូង ច្រានចោលបណ្តឹងជំទាស់ និងសំណើរបស់មេធាវីការពារក្តី អៀង សារី ថាមិនអាចឲ្យទទួលយកបានឡើយ គ្មានមូលដ្ឋានជាក់ស្តែង បង្អាក់ដំណើរការ និង/ឬ មិនស្ថិតក្នុងផលប្រយោជន៍នៃយុត្តិធម៌៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** William SMITH សហព្រះរាជអាជ្ញារង | | [signature] |